# វិប្បដិសារី

...នៅក្នុងឆ្នាំ ១៩៧៤ **សម-ប៊ុន** ជានិស្សិតពេទ្យសត្វឆ្នាំទី៤ នៅចំការដូង (Etudiant en 4ème année à l'école vétérinaire de Chamcar Daung) ។ ឆ្នាំទី៤ ជាឆ្នាំទីបញ្ចប់ ។ ឪពុកម្តាយ**សម-ប៊ុន** ជាអ្នករកស៊ីលក់ចេញ-ទិញចូល ( កុងស៊ីបញ្ញាំ-Brocanteur ) នៅក្បែរផ្សារស៊ីឡិប ភ្នំពេញ...។

កាលនៅក្នុងឆ្នាំ ១៩៦៩ គាត់រកស៊ីកាក់កបណាស់ដោយសារមាន "កាស៊ីណូ" នៅផ្សារកាប់គោ...។ ឪពុកម្តាយ**សម-ប៊ុន** ធ្លាប់កោតសរសើរស្ញប់ស្ញែងព្រះបាទ នរោត្តម **សីហនុវ្ម័ន** ជាអតិបរមា ព្រោះព្រះអង្គមានប្រាជ្ញាឈ្លាសវៃដ៏អស្ចារ្យ បង្កើតរោងល្បែងស៊ីសង នៅទន្លេចតុមុខ ជាហេតុធ្វើឱ្យគាត់ក្លាយជាអ្នកមានលុយកាក់នឹងគេ... ចាយយ៉ាងណាក៏មិនអស់ដែរ ។

# ត្រឡប់ចូលក្រុងភ្នំពេញវិញ

*"ផ្គរលាន់ឯជើងរលើងទាំងឫស*
*ទមិឡ (អានថាថ្មិល) ទាំងប្រាំបីទិស*
*នាំគ្នាចូលក្រុង ។*
*...មិនថាខែចេត្រឬខែផល្គុន*
*នាំគ្នាចូលក្រុង*
*សម្លាប់រាស្ត្រខ្មែរ"...*

...ថ្ងៃមួយនោះ គឺចុងឆ្នាំ ១៩៧២ ម្ដាយ**សម-ប៊ុន**និយាយទៅកាន់ប្ដី :

- ប៉ាវាអ្ហ៎! ខ្ញុំគិតរកប្រពន្ធឱ្យ**សម-ប៊ុន**ហើយ ។
- ម៉ាក់វាគិតដណ្ដឹងកូនអ្នកណា?
- ខ្ញុំគិតដណ្ដឹងកូនលោកឧត្ដមសេនីយ៍ **ធុយ-ឡែម** ឱ្យកូនយើងណា៎ប៉ាវា ។
- ខ្ញុំដូចជាមិនសូវស្រឡាញ់ទេគ្រួសារទាហាន ម៉ាក់វាអើយ! បើដណ្ដឹងកូនថៅកែសាំង **ហ-ណាំ** វិញប្រហែលល្អជាង... ព្រោះថៅកែនេះមានលុយសម្បើមហើយ ។



- យីប៉ាវានិយាយម៉េចអីចឹង? ឧត្ដមសេនីយ៍ **ធុយ-ឡែម** មានខ្លាំងណាស់សព្វថ្ងៃនេះ ។ លុយបានមកពីលួច "អែហ្វហ្វិចទិហ្វ = Effectif" និងលួចលក់គ្រាប់ឱ្យខ្មែរក្រហម យ៉ាងអន់ណាស់ក៏បានចូលមួយបាវដែរក្នុងមួយថ្ងៃ ។ ចំណែកភូមិគ្រឹះរបស់គាត់ដែលទើបនឹងសង់...ហើយ នៅក្បែរមហាវិទ្យាល័យគរុកុសល្យនោះវិញឮថាអស់ដល់ទៅ ៥កោដិរៀលឯណោះ ។
- ម៉ែវាអ្ហ៎! បើយើងដណ្ដឹងកូនចិនដូចជាគ្រាន់បើជាងកូនខ្មែរ... ព្រោះកូនចិនវាចេះរកស៊ីមិនសូវល្ងង់ទេ ។ ឧត្ដមសេនីយ៍ **ធុយ-ឡែម** ស្បែកខ្មៅព្រឹក ពិតជាខ្មែរសុទ្ធ ។
- ប៉ាវាឯងកុំមើលងាយខ្មែរណា៎! បើខ្មែរល្ងង់មិនមែនខ្មែរសង់**អង្គរវត្ត**កើតទេ ។ ចុះ... ឪពុកម្ដាយប៉ាវាឯងក្រែងមានដើមកំណើតមកពីស្រុកស្រែចំការឬទេអី? កុំអាលភ្លេចកំណើតរបស់ខ្លួនពេក !
- ខ្ញុំមិនសូវដឹងទេ ស្រេចតែម៉ែវាឯងទៅចុះ ។
- ម្ដាយ**សម-ប៊ុន**ញញឹមខ្ញីប នឹករវើរវាយដល់កូនចេញធ្វើពេទ្យសត្វ ថាច្បាស់ជានឹងបានសាច់គោ សាច់ជ្រូក សាច់មាន់ សាច់ទាស៊ីទទេ ព្រោះចិនព្រិនពិតជាយកមកសែនកូនគាត់រៀងរាល់ថ្ងៃមិនខានឡើយ ។

ពីរសប្តាហ៍ក្រោយមក ឪពុកម្តាយ**សម-ប៊ុន** ក៏ទៅសុំស្តីដណ្តឹងកូនលោកឧត្តមសេនីយ៍ **ធុយ-ឡែម** ឱ្យកូនរបស់ខ្លួន ។ នៅពេលគាត់ឈានជើងចូលទៅក្នុងផ្ទះ ឪពុក**សម-ប៊ុន**សក់ច្រូង ព្រោះភូមិគ្រឹះនេះល្អហួសពីការស្មាន ។ ការ៉ូ វាំងនន សុទ្ធសឹង "ម៉ាកអ៊ិនហ្វ្រង់ = Made in France" ។ តុទូ កៅអី សុទ្ធតែ "ស្ទីល = Style" ជំនាន់ល្វីទី១៤ (Louis XIV) ដែលសង់ប្រាសាទ "វៀរសៃ" (Versailles) នៅចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីទីក្រុងប៉ារីស៍ (Paris) ។ ក្នុងសួនច្បារមានផ្កាវីកស្គុះស្គាយនិងដាំស្មៅពណ៌ខៀវខ្ចីដែលដឹកមកពីប្រទេសសៀម។

គួរអស្ចារ្យមែន!! នៅពេលដែលស្រុកកំពុងច្បាំង និងអត់បាយក្រហាយទឹក គ្រួសារឧត្តមសេនីយ៍**ធុយ-ឡែម** រស់នៅមិនខុសពីអធិរាជ **"ណាប៉ូឡេអុង"** ឡើយ ។

លោកជំទាវ **ធុយ-ឡែម** រាក់ទាក់នឹងភ្ញៀវខ្លាំងណាស់ ។ ក្រោយពីជជែកគ្នាបានបន្តិច... ឪពុកម្តាយ**សម-ប៊ុន**ក៏ចាប់ចូលដល់សាច់ការគឺ "ការសុំផ្លូវដណ្តឹរឡើង" ។ លោកជំទាវ **ធុយ-ឡែម** ក៏ឥតមានយល់ទាស់ ព្រោះចង់រៀបចំទុកដាក់កូនស្រីឱ្យមានគូស្រករដែរ។ បន្តិចក្រោយមកនាង **រ៉ូស្ថាលីន** បុត្រីឧត្តមសេនីយ៍លើកទឹកតែមកជូនភ្ញៀវ ។



\- **អារ៉ូ** (លោកជំទាវនិយាយទៅកាន់កូន) កូនចាក់ទឹកតែជូនអ៊ុំប្រុស-ស្រីទៅ...

\- ឪពុកម្តាយ**សម-ប៊ុន**សម្លឹងមើលអនាគតកូនប្រសារ.... ដោយពេញចិត្តជាទីបំផុត ។

នាង **រ៉ូស្ថាលីន** ជានារីមួយរូបដែលមានរូបឆោមលោកពណ៌ល្អគួរឱ្យគយគន់ ។ សម្បុរសណ្តែកបាយ... ភ្នែកធំ សក់ស្លូតធ្លាក់ប្រាសស្មា រូបរាងខ្ពស់ស្រឡះ ។ នាងពិតជាមានសម្ផស្សរបៀបនារី ខ្មែរសុទ្ធសាធ ។ នាងរៀននៅថ្នាក់ទីបញ្ចប់នៅវិទ្យាល័យ "ដេសកាត" (Lycée Descartes) ។ ចំណែក **សម-ប៊ុន**វិញ គេក៏ជាកំលោះមួយរូបយ៉ាងសង្ហាដែរ ។ គូស្រករនេះពិតជាសមគ្នាមែន... ។

រៀងរាល់ថ្ងៃអាទិត្យ **សម-ប៊ុន** តែងតែទៅលេងផ្ទះឧត្តមសេនីយ៍ **ធុយ-ឡែម** ជួយបង្រៀនអនាគតភរិយារបស់គេដោយយកចិត្តទុកដាក់ជាទីបំផុត ។ សេចក្តីស្នេហាដ៏បរិសុទ្ធរវាងយុវជន-យុវនារីទាំងពីរក៏ចាប់បដិសន្ធិបន្តិចម្តងៗរហូតដល់គេបែកគ្នាមួយថ្ងៃសឹងពុំបានផង ។ គេទាំងពីរនាក់ទន្ទឹមរង់ចាំតែថ្ងៃរៀបការមកដល់នឹងអាលនាំគ្នាដើរលេងនៅឋានលើ ។

ថ្ងៃមួយនោះ លោកជំទាវ **ធុយ-ឡែម** ក៏រកគ្រូគន់គូរមើលថ្ងៃជាវេលាល្អ ដើម្បីនឹងរៀបអាពាហ៍ពិពាហ៍កូនស្រីគាត់ ។ អាចារ្យទាយថា ថ្ងៃដែលល្អបំផុតនោះ គឺថ្ងៃកោរ ១៣រោជ ខែចេត្រ ពុទ្ធសករាជ ២៥២០ ត្រូវនឹងថ្ងៃទី ១៥ ខែមេសា ឆ្នាំ ១៩៧៥ ។

ថ្ងៃចូលរោងមកដល់ ភ្លេងតូរ្យតន្ត្រីក៏ចាប់ផ្ដើមលេង ។ ស្នូរស្គរសំភោប្រណាំងប្រជែងនឹងស្នូរគ្រាប់រ៉ុក្កែត ១២២មីលីម៉ែត្រ ដែលធ្លាក់មកពួស្នូរក្នុងក្ដាំងលើទីក្រុងភ្នំពេញ ។ ទោះជាគ្រាប់រ៉ុក្កែតធ្លាក់យ៉ាងដូចម្ដេចក៏ដោយក៏គេឃើញភ្ញៀវមកយ៉ាងកុះករ ហាក់ដូចជាគ្មានភ្ញាក់ផ្អើលនឹងស្ថានការណ៍ដ៏ធ្ងន់ធ្ងរទាំងនេះសោះ ។ អស់លោកនាយទាហានជាន់ខ្ពស់ និងអស់លោកឧត្តមសេនីយ៍នាំគ្នាបញ្ចេញឫទ្ធិសំញែងបង្អួតគ្នានូវឡានថ្មីៗស្រឡាងៗ ដោយគ្មានការខ្មាសអៀនបន្តិចបន្តួចសោះឡើយ ។

នៅពេលរាត្រីផ្សំដំណេក គ្រាប់បែកធ្លាក់កាន់តែខ្លាំងឡើងៗ តែនាង **រ៉ូស្នាលីន** និង **សម-ប៊ុន** ឥតមានឮស្នូរអ្វីឡើយ ព្រោះគេទាំងពីរនាក់កំពុងតែនាំគ្នាហែលទឹកលេងយ៉ាងសប្បាយ នៅក្នុងសមុទ្រសាគរដែលព្យុះសង្ឃរាបោកបក់មកយ៉ាងខ្លាំង ។ ទឹករលកបែកផ្កាត្រែងរត់មកប៉ះនឹងដុំថ្មបែកខ្ចាយសំពោងសំពាយ ។ មច្ឆាតូចធំទាំងប៉ុន្មានភ័យ ស្លន់ស្លោនាំគ្នារត់ទៅពួនអាត្មានៅឯបាតសមុទ្រ ។

សប្បាយអើយសប្បាយអ្វីម្ល៉េះទេ!



ព្រឹកថ្ងៃទី ១៧ មេសា ១៩៧៥ នៅពេលដែលអ្នកទាំងពីរក្រោកសើងម៉ើងពីដំណេក ស្រាប់តែគេឃើញមនុស្សដើរមីរដេរដាស..... ខ្លះទូល ខ្លះរែក ខ្លះពុន ខ្លះដឹកដៃកូន ដើរពាសពេញនៅតាមផ្លូវ ។ លោកជំទាវ **ធុយ-ឡែម** រត់រលះរលាំងទៅប្រាប់កូន-កូនប្រសាឱ្យរៀបចំឥវ៉ាន់ដាក់ឡាន "មែរសេដែស" (Mercedès) ព្រោះខ្មែរក្រហមចូលដល់បេះដូងភ្នំពេញហើយ ហើយចាប់ដេញប្រជាជនចេញពីទីក្រុង ។ អ្នកណាហ៊ានរឹងទទឹងត្រូវពួកវាបាញ់សម្លាប់ចោលមួយរំពេច ។ លោកជំទាវ **ធុយ-ឡែម** យកលុយបួនបាវ (បាវអង្ករ ២៥គីឡូ) និងមាសមួយកញ្ចប់ធំបោះចូលទៅក្នុងឡាន... បម្រុងទៅធ្វើអ្នកមានម្ដងទៀត... នៅស្រុកទមិឡ ។ ក្រៅពីប្រពន្ធ**សម-ប៊ុន** ឧត្តមសេនីយ៍ **ធុយ-ឡែម** មានកូនប្រុសបីនាក់ទៀត ដែលនៅតូចៗនៅឡើយ ។ លោកជំទាវចាកចេញពីភូមិគ្រឹះទាំងទឹកភ្នែក ព្រោះនឹកស្ដាយអាឡោះអាល័យទ្រព្យសម្បត្តិមហាសាល.... ដែលបានពីលួចជាតិ ។

លុះមកដល់ក្បាលថ្នល់...គេឃើញអង្គការបិទប្រកាសអំពាវនាវរកពួកនាយទាហានឱ្យចូលទៅភ្នំពេញដើម្បីបម្រើអង្គការ ។ ឧត្តមសេនីយ៍ **ធុយ-ឡែម** សប្បាយចិត្តឥតឧបមានឹកស្មានថាអង្គការពិតជាមិនដកផ្តាយពីលើស្នាគាត់ទេមើលទៅ ។ គាត់ក៏លាគ្រួសារចូលទៅបម្រើអង្គការដ៏មហាភ្លឺស្វាងបាត់រហូតទៅ ក្រោយពីឪពុកក្មេកចូលទៅភ្នំពេញវិញ **សម-ប៊ុន** និងភរិយាព្រមទាំងប្អូនថ្លៃនាំគ្នារុញឡាន "មែរសេដែស" ថ្មីស្រឡាងបន្តទៅមុខទៀត ព្រោះឡានអស់សាំង ។

ព្រះអាទិត្យ ក្នុងខែមេសា បញ្ចេញចំហាយក្តៅខ្លាំងយ៉ាងមហិមា.... **សម-ប៊ុន** និងភរិយាបែកញើសជោកខ្លួនប្រាណដោយសារខំរុញឡាន ។ នៅពេលឈប់សម្រាកក្រោមដើមឈើ... នាង **រ៉ូស្នាលីន** ស្ទុះទៅដណ្តាំស្ល ថ្វីបើស្ថានការណ៍ធ្លាក់មកដល់ថ្នាក់នេះក៏ដោយ នាង **រ៉ូ** ខំថ្នាក់ថ្នមប្តីខ្លាំងណាស់...។ **សម-ប៊ុន** អង្គុយរវើរវាយក្រោមដើមឈើប្រទេចផ្កាសាអាចារ្យ ដែលទស្សន៍ទាយថាថ្ងៃ ១៥ មេសា ជាថ្ងៃជាវេលាល្អសម្រាប់អាពាហ៍ពិពាហ៍របស់គេ។ បើសិនណាជាអាចារ្យចោលស្រុកនោះទាយថា ថ្ងៃរៀបការមុខថ្ងៃ ១៥ មេសា តែមួយអាទិត្យក៏អស់ចិត្តដែរ ព្រោះយ៉ាងហោចណាស់ក៏គេបានសប្បាយបួនប្រាំថ្ងៃជាមួយភរិយារបស់គេនៅក្នុងវិមានដ៏ស្ដឹមស្ដៃ



នោះដែរ ។ ឥឡូវស្រាប់តែនាំគ្នាមកដេកលើដីប្រជ្រៀតគ្នាស្អេកស្កះរកតែងាកខ្លួនពុំរួចផង... ។ ក្រោយពីប្រទេចផ្កាសាអាចារ្យអស់ចិត្តមក **សម-ប៊ុន** ក៏ចាប់ជេរពួកអាខ្មែរក្រហមថា ពួកទមិឡបានមកបំផ្លិចបំផ្លាញសុភមង្គលរបស់គេ ។

មួយអាទិត្យក្រោយមកគ្រួសារ **សម-ប៊ុន** ក៏នាំគ្នារុញឡានមកដល់ភូមិសំប៉ាន ក្នុងខេត្តកណ្តាល ។ មកដល់ភូមិនេះមិនទាន់បានស្រួលបួលផង អង្គការក៏ស្នើឡាន "មែរសដែស" ដើម្បីគាស់យកកង់ធ្វើ "ស្បែកជើងហូជីមិញ" ។

- មិត្តឯងកុំស្តាយស្នើអាឡានប៉ុណ្ណឹងនោះ បន្តិចទៀត... អង្គការដាំចេកយកទៅជូរឡានហើយ ។ ក្នុងអនាគតដ៏ខ្លីនេះ អង្គការមិនខ្វះឡានប្រើទេ ។

អង្គការក៏ចាប់រៀបចំឱ្យពួកអ្នកភ្នំពេញនៅក្នុងភូមិជាបណ្តោះអាសន្ន ។ ម្តាយក្មេក **សម-ប៊ុន** ខំដេរខ្នើយយកលុយមកញាត់ជំនួសសំឡី ព្រោះគាត់សង្ឃឹមថា អង្គការច្បាស់ជាអនុញ្ញាតឱ្យចាយលុយឡើងវិញពុំខានឡើយ ។ គឺជាការចៃដន្យមួយថ្ងៃក្រោយមកគ្រួសាររបស់មា **សម-ប៊ុន** ក៏បានមកដល់សំប៉ានដែរ ។ គ្រួសារទាំងពីរក៏ត្រូវបានអង្គការអនុញ្ញាតឱ្យទៅជាមួយគ្នាក្រោមផ្ទះក្បឿងដ៏ធំមួយ ។ លោក**ប្រាក់-ឱន**ត្រូវជាប្អូនបង្កើតរបស់ម្តាយ**សម-ប៊ុន...**

ហើយធ្លាប់ធ្វើការនៅអគ្គិសនីកម្ពុជា (EDC) និងរដ្ឋករទឹក (Régie des Eaux) ឯទីក្រុងភ្នំពេញ ។ គាត់ជាអ្នកបច្ចេកទេសដ៏សំខាន់ម្នាក់នៅក្នុងក្រសួងទាំងពីរនេះ ។ ថ្ងៃមួយនោះអង្គការបានអំពាវនាវរកអ្នកបច្ចេកទេសខាងទឹកនិងភ្លើង ព្រោះជាងមួយខែហើយដែលទីក្រុងភ្នំពេញឥតមានភ្លើងនិងទឹកប្រើប្រាស់ ។ ខ្មែរក្រហមគេចង់សាកទឹកម៉ាស៊ីននិងភ្លើងឆេះឯង ។

គ្រួសារលោក**ប្រាក់-ឌិន** និង **សម-ប៊ុន...** ក៏បានត្រូវអង្គការមហាក្ដីស្វាងនាំទៅភ្នំពេញវិញ ។ ទៅដល់ក្បាលថ្នល់ **សម-ប៊ុន** ព្រឺក្បាលខ្វាកដោយសារសភាពស្ងាត់ជ្រងំ និងខ្មោចហើមស្អឹងនៅតាមផ្លូវមិនទាន់មាននរណាយកទៅកប់នៅឡើយ ។ **សម-ប៊ុន** ចេះតែខំសង្កេតនៅជុំវិញខ្លួន តែគ្មានឃើញអ្វីឡើយក្រៅពីសភាពអាណោចអធ័ម ផ្ទះបាក់បែក.. សសរដងគោមអគ្គិសនីដួលរាយប៉ាយនៅលើដីមែកឈើចាកដើម សំបកកាំភ្លើងរ៉ុក្កែត ខោអាវទាហាននៅពាសពេញផ្លូវ។ កន្លែងខ្លះភ្លើងឆេះនៅឡើយ។ យូរៗគេឃើញខ្មែរក្រហមម្នាក់ស្ពាយកាំភ្លើងអូសជីរបៀបខ្ជិល។ នេះពិតដូចជាពុទ្ធទំនាយមែន:

***មានផ្ទះឥតមនុស្សនៅ មានផ្លូវឥតមនុស្សដើរ ។***

គ្រួសារទាំងពីរនាក់បានត្រូវអង្គការឱ្យមកសំណាក់នៅឯវិទ្យាល័យ **ស៊ីសុវត្ថិ** ។ លោក **ប្រាក់-ឌិន** មុនដំបូងដូចជាសប្បាយ...



លុះមកដល់ភ្នំពេញស្រាប់តែចាប់ភ័យ ព្រោះភ្នំពេញក្លាយទៅជាទីក្រុងខ្មោច ។ គេឮតែសម្លេងខ្យល់បក់វូរៗ... យូរៗឮសូរសម្លេងកាំភ្លើងពីរបីគ្រាប់ ប្រហែលជាខ្មែរក្រហមបាញ់សម្លាប់នាយទាហានឡីគីដែលចូលមកបម្រើអង្គការ... មានលោកឧត្តមសេនីយ៍ **ធុយ-ឡែម** ជាដើមក៏មិនដឹង ។ ម្ដាយក្មេក**សម-ប៊ុន**ក្ដី ប្រពន្ធ**ប្រាក់-ឌិន**ក្ដី មុខឡើងស្លាំងលែងចង់និយាយរកគ្នា ព្រោះម្នាក់ៗចេះតែមានអារម្មណ៍រវើរវាយគិតផ្ដេសផ្ដាស ។

ខ្យល់បក់មកយ៉ាងខ្លាំង គ្រាប់ភ្លៀងប៉ុនៗមេដៃក៏ចាប់ធ្លាក់មកលើដំបូលអាគារវិទ្យាល័យ បណ្ដាលឱ្យឮសូរសម្លេងមិនខុសពីគេយកគ្រាប់គ្រួសទៅគប់លើដំបូលផ្ទះ ។ ភ្លៀងមួយយប់ទាល់ភ្លឺ ។ នៅពេលព្រះអាទិត្យរះដល់ចុងឈើ គេឃើញខ្មែរក្រហមពីរនាក់យកស្បៀងមកឱ្យគ្រួសារលោក **ប្រាក់-ឌិន** : អង្ករមួយបាវ អំបិលស្ករ និងត្រីងៀត ។ លោក **ប្រាក់-ឌិន** ខំអស់ពីសមត្ថភាព ដើម្បីជួសជុលម៉ាស៊ីនភ្លើងឡើងវិញ... ។ នៅពេលព្រះអាទិត្យ អស្ដង្គតទីក្រុងភ្នំពេញមួយភាគធំបានធ្លាក់ចូលក្នុងភាពអន្ធការ ហើយមានសភាពស្ងាត់ជ្រងំគួរឱ្យភ័យតក់ស្លុត ។ គេឃើញតែអាគារធំៗលេចឡើងយ៉ាងត្រដែតនៅក្នុងភាពងងឹតសូន្យសុង ។ អនិច្ចា! ទីក្រុងភ្នំពេញមិនគួរមកស្លាប់ដូច្នេះសោះ ។

**សម-ប៊ុន**និងភរិយានឹកស្ដាយក្រោយថា មិនសមដាច់ចិត្តចូលមកភ្នំពេញ បើនៅជាមួយគេឯងឯស្រុកស្រែចំការប្រហែលធូរចិត្តជាង ។ នៅពេលរាត្រីកាលចូលមកដល់ម្ដងៗ នាងរ៉ូព្រឺក្បាលខ្វាក់ៗនឹងសម្លេងតុកកែ និងបក្សីរាត្រីចរឯទៀតៗដែលហើរមកជ្រកនៅលើដើមឈើធំៗក្នុងទីលានសាលា ។ នៅពេលផ្ទើដំណើរទៅកាន់រោងចក្រអគ្គិសនីម្ដងៗ **សម-ប៊ុន** តែងតែឆ្លៀតឱកាសចោលភ្នែកមើលគ្រប់ទិសទីក្រែងឃើញពួកទាហាន **លន់-នល់** ដែលចូលមកបម្រើអង្គការ ។ ថ្ងៃមួយនោះ **សម-ប៊ុន** ឃើញមនុស្សក្បាលត្រងោលមួយក្រុមកំពុងតែទាញលួសបន្លានៅមុខក្រសួងឃោសនាការ ។ ខ្មែរក្រហមក្មេងៗបីបួននាក់ឈរយាមយ៉ាងហ្មត់ចត់ ដោយភ្ជង់កាំភ្លើងទៅរកពួកទាំងនោះ...។ ក្រោយមកទើបគេដឹងថា ពួកក្បាលត្រងោលទាំងនោះជាពួកនាយទាហានរបស់ **លន់-នល់** ។ ពួកនេះត្រូវពួកខ្មែរក្រហមយកទៅវាយក្បាលនឹងត្បូងចបនៅលើស្ពាន **មុនីវង្ស** រួចទម្លាក់ទៅក្នុងទឹកទន្លេ **បាសាក់** ដើម្បីជាចំណីត្រី ។

ប្រាំខែក្រោយមក គឺនៅខែកញ្ញា ១៩៧៥... អង្គការក៏បញ្ជូនគ្រួសារលោក **ប្រាក់-ឌិន** និង **សម-ប៊ុន** ឱ្យមកភូមិសំប៉ានវិញ ព្រោះលោក **ប្រាក់-ឌិន** បានបង្ហាត់បង្រៀនខ្មែរក្រហមឱ្យចេះប្រើម៉ាស៊ីនភ្លើងនិងទឹកខ្លះៗហើយ ។



## មិត្តនារីនាប

"...

*មើលភ្នំធំធេងវែងរលីក មើលទឹករលករលាមសាយ*
*មើលដីដីដុះវែងអន្ទាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី*

..."

**សេកសោមបណ្ឌិត**

...គឺជារដូវវស្សា ។ ទឹកទន្លេមេគង្គកំពុងតែឡើងខ្លាំង ។ ទឹកហូរចូលអូរ ចូលព្រែក ចូលក្រោមផ្ទះអ្នកស្រុកនៅតាមមាត់ទន្លេ ។ ជីវភាពនៅខេត្តកណ្ដាលមានការចុះអន់ថយជាអតិបរមា ដោយសារវត្តមានអ្នកភ្នំពេញដែលមកនៅកុះករ ។ គេនាំគ្នាបរិភោគពោត ជួនកាលពោតលាយបាយនឹងត្រកួន មិនខុសពីបាយជ្រូក ។ តែការមួយដែលគួរកត់សំគាល់ គឺអ្នកទន្លេមានចិត្តទូលំទូលាយ មិនស្អប់ពួកអ្នកភ្នំពេញ ទោះខ្វះមុខខ្វះក្រោយដូចម្ដេច ក៏ចេះតែជួយរំលែកចែកចាយ

ដល់អ្នកថ្មី គឺជាការដ៏ល្អប្រសើរដែលគេពុំសូវប្រទះនៅក្នុងតំបន់ស្រុកស្រែឬព្រៃភ្នំ ។

ថ្ងៃមួយនោះ នៅព្រឹកព្រហាមស្រាប់តែគេឃើញកាណូតទូកថ្ងៃដើរដោយម៉ាស៊ីនជាច្រើនគ្រឿងមកចតមីរដេរដាសនៅតាមមាត់ទន្លេ ។ បន្ទាប់មកគេឮសូរសម្លេងអំពាវនាវតាមមេក្រូឱ្យអ្នកថ្មីរៀបចំអីវ៉ាន់ឡើងទូកកាណូត ព្រោះអង្គការលើកទិសដឹកនាំអ្នកថ្មីទៅរកកន្លែងសុខសាន្ត កន្លែងសម្បូរសប្បាយហូរហៀរទៅដោយស្រូវអង្ករ គឺខេត្តបាត់ដំបង ។ ឮតែខេត្តបាត់ដំបង **សម-ប៊ុន** ញញឹមខ្ញីបនឹកអរព្រួចថា មុខជាបានហូបបាយលែងហូបបបរជ្រូកទៀតហើយ ។ ម្យ៉ាងទៀត គេមានបំណងសម្ងាត់មួយគឺរត់ទៅស្រុកសៀម ព្រោះតាំងពីត្រឡប់មកពីភ្នំពេញវិញ **សម-ប៊ុន** យល់ច្បាស់ណាស់ថា អង្គការពិតជាក្រុមនិកាយខ្មៅ ជាបក្សទុច្ចរិតមិនខុសពីរឿងកាប់ដាវចិននោះទេ ។

ក្បួនទូកកាណូតចាប់កម្រើកម៉ាស៊ីនរោទិ៍យ៉ាងខ្លាំង។ មនុស្សកុះករប្រច្រៀតគ្នាចង្អៀតដូចកាតំ ខ្លះនៅក្នុងទូក ខ្លះនៅលើដំបូលខ្លះនៅខាងកន្សែ ខ្លះនៅខាងមុខ ។ កូនក្មេងស្រែកយំពេញទូក ។ គ្រួសារ **សម-ប៊ុន** និងលោក **ប្រាក់-ឌិន** នៅលើដំបូល ។ គេនាំគ្នាធ្វើដំណើរបញ្ច្រាសទឹកតាមទន្លេបាសាក់ ដែលនៅរដូវវស្សាបានក្លាយទៅជាសមុទ្រដ៏តូច មានពណ៌ប្រផេះដូចពណ៌ដី ។ ទឹកទន្លេហូរខ្លាំងណាស់ ហាក់ដូចជាបញ្ចេញឫទ្ធិទប់ទូកអង្គការដ៏មហិមាកុំឱ្យធ្វើដំណើរលឿនទៅមុខពេក ។ **សម-ប៊ុន** នៅលើដំបូលទូកចោលភ្នែកមើលទិដ្ឋភាពនៅជុំវិញខ្លួន ។ វត្តអារាមបាក់បែក វិហារផ្ទះធ្លាយទៅដោយគ្រាប់កាំភ្លើង ។ ផ្ទះអ្នកស្រុករខេករខាក ។ ឱ! ស្រុកយើងអើយ...! ភូមិសំប៉ាននកាន់តែឆ្ងាយទៅៗ... រីឯទីក្រុងភ្នំពេញក៏កាន់តែជិតមកដល់ដែរ ។ តែពេលនេះ **សម-ប៊ុន** គ្មានក័ព្វសំណាងបានទៅនៅរួមរស់ជាមួយវាទៀតទេ ។ នៅពេលនាវាបើកទៅដល់ទន្លេបួនមុខ សម្លេងញ៉េចញ៉ាចនៅលើទូកស្រាប់តែរលត់ឈឹង ព្រោះម្នាក់ៗខំនាំគ្នាសម្លឹងមើលភ្នំពេញសឹងលែងដកដង្ហើម ។ អ្នកខ្លះស្រក់ទឹកភ្នែក អ្នកខ្លះយំខ្សឹកខ្សួលអាឡោះអាល័យទ្រព្យសម្បត្តិ ផ្ទះសម្បែង និងទឹកដីដែលធ្លាប់រស់នៅអស់ជាច្រើនជំណា ។ ក្បួននាវាចេះតែរំកិលនៅមុខនៅលើផ្ទៃទឹកទន្លេសាប ។ ភ្នំពេញកាន់តែតូចទៅតូចទៅ លុះត្រាតែផុតកន្ទុយភ្នែក ។ លាហើយ! លាហើយ! ភ្នំពេញអើយ! សូមអ្នកនៅឱ្យបានសុខជាមួយអង្គការដ៏មហាភ្លីស្វាង ។

នៅពេលព្រះអាទិត្យអស្តង្គត នាវាចូលចតសម្រាកតាមមាត់ច្រាំង រហូតដល់ថ្ងៃរះទើបធ្វើដំណើរតទៅទៀត ។ អស់រយៈជាច្រើនថ្ងៃ ក្បូននាវាបានបើកមកដល់ខេត្តកំពង់ឆ្នាំង ។ អង្គការប្រកាសប្រាប់អ្នកជន្លៀសថា : *"បងប្អូនបានមកដល់ទិសដៅហើយ! សូមនាំគ្នារៀបចំអីវ៉ាន់ឡើងគោក"* ។ អ្នកភ្នំពេញមីរដេរដាសទាំងចាស់ទាំងក្មេង ដោយមានខ្មែរក្រហមបួនដប់នាក់ជាអ្នកបញ្ជា បាននាំគ្នាមកដល់ចំណតរទេះភ្លើងកំពង់ឆ្នាំង ។ នៅទីនោះគេឃើញរទេះភ្លើងមួយខ្សែយ៉ាងវែងបញ្ឈេះចាំជាស្រេច ។ ខ្មែរក្រហមបញ្ជាឱ្យអ្នកភ្នំពេញឡើងរទេះភ្លើងដើម្បីប្រញាប់ធ្វើដំណើរទៅកាន់បាត់ដំបង ។ រទេះភ្លើងបើកទៅមុខយឺតៗ ។ មិនដឹងជាប៉ុន្មានម៉ោងក្រោយមក រទេះភ្លើងបានមកឈប់នឹងចំណតមួយទៀត ។ អង្គការបានប្រកាសក្តែងៗទៀតថា : *"ឥឡូវនេះបងប្អូនបានមកដល់ទីដៅមែនទែនហើយ ។ អង្គការលើកទិសឱ្យបងប្អូនមកបង្កបង្កើតផលនៅទីនេះ"*។ គ្រាន់តែអង្គការនិយាយចប់ភ្លាមម្នាក់ៗមុខឡើងស្លេក ជាពិសេសគ្រួសារ **សម-ប៊ុន** និងលោក **ប្រាក-ឌិន**។ តើអង្គការឱ្យអញមកនៅទីនេះយ៉ាងដូចម្តេច បើគ្មានអ្វីក្រៅពីវាលស្មៅដ៏ល្ហល្ហេវ និងភ្នំមួយយ៉ាងធំដែលមានដើមឈើដុះខៀវងងឹត ។ អ្នកដែលធ្លាប់ធ្វើដំណើរតាមរទេះភ្លើងទៅកាន់ក្រុងបាត់ដំបង កាល



ស្រុកមិនទាន់ច្បាំងស្គាល់ភ្នំនេះច្បាស់ណាស់គឺ **ភ្នំធិបតី** (អានថាធិបដេ) ។ គួរកត់សំគាល់ថា ក្នុងចំណោមអ្នកភ្នំពេញទាំងអស់មានចិនប្រហែល ២០% ។

ថ្ងៃបន្ទាប់មកទៀត គេឃើញរទេះភ្លើងដឹកអ្នកភ្នំពេញមកទម្លាក់ចោលនៅទីនេះជាច្រើនដង... មនុស្សរាប់ពាន់នាក់នាំគ្នាកាប់ឈើកាប់ឫស្សីមកធ្វើខ្ទម ក្រោមការត្រួតត្រារបស់មិត្ត **ភុន** ខ្មែរក្រហមដ៏ឆ្អិនឆ្អៅ ។ មិត្ត **ភុន** មិនចេះស៊ីទេលុយ... ចេះតែប្រាស់ច្រំនាឡិកា និងមាស ។ នាឡិកាម៉ាកអូម៉េក្កា (Oméga) ឬរ៉ូឡេច (Rolex) មិត្ត **ភុន** ឥតយកភ្នែកមើលឡើយ.... បើបានអាម៉ាកអូរីយ៉ង់ (Orient) ឬ ស៊ីទីហ្សែន (Citizen) មិត្ត **ភុន** ញញឹមខ្ចីប ។ អង្គការលើកទិសឱ្យអ្នកថ្មីមកកាប់ឈើជម្រះស្មៅធ្វើស្រែ.... នៅ**ភ្នំធិបតី** ចំណែកស្រែរាប់ពាន់ហិកតាដែលមានមកពីយូរមកហើយ អង្គការមិនឱ្យអ្នកភ្នំពេញធ្វើទេ ទុកឱ្យស្មៅដុះជុក!

យើងចូលមកដល់ពាក់កណ្តាលឆ្នាំ ១៩៧៦ អ្នកភ្នំពេញស្លាប់អស់ជាងពាក់កណ្តាលដោយសារការអត់បាយ ជម្ងឺ និងការសម្លាប់រង្គាល ។

គ្រួសារលោក **ប្រាក់-ឌិន** ស្លាប់ផុតពូជ ។ បន្ទាប់មកប្អូនថ្លៃ **សម-ប៊ុន** ទាំងបីនាក់ ។ លោកជិទាវ **ធុយ-ឡែម** ដោយសារមាន

ការពិបាកចិត្តខ្លាំងពេកក៏ធ្វើអត្តឃាត ។ នៅសល់តែ **សម-ប៊ុន** និងប្រពន្ធដែលប្រឹងប្រយុទ្ធតស៊ូជាមួយនឹងការរស់នៅតទៅទៀត ។

ក្រោយពីម្តាយនិងប្អូនស្លាប់ចោលទៅ នាង **រ៉ូ** ហាក់ដូចជាវង្វេងស្មារតីភ្លេចមុខភ្លេចក្រោយ ។ **សម-ប៊ុន** តែងតែលួងលោមភរិយា ដោយលើកយកធម៌ព្រះមកពន្យល់ប្រពន្ធ :

***"សព្វេហិមេបិយេហិមនាបេហិនានាភាវោ...វាវាភាវោ"***

ប្រែថា :

***"សព្វសត្វទាំងឡាយតែមានការព្រាត់ប្រាស ចាកចោលរបស់ជាទីស្រឡាញ់ជាទីពេញចិត្តជាធម្មតា ព្រោះថាមនុស្សសត្វទាំងឡាយមិនអាចនៅជួបជុំទាំងកប្បទាំងកល្បបានឡើយ..."*** ។

ជាការធម្មតាទេ... ពេលកើតទុក្ខ ពេលឈឺមនុស្សតែងរត់រកព្រះ ។ លុះផុតទុក្ខ ខ្ញុំព្រះករុណាសុំ *"បាយ-បាយ"* ព្រះអង្គសិនហើយ ។

ថ្ងៃមួយ **សម-ប៊ុន** និយាយទៅកាន់ប្រពន្ធ :

- អូន **រ៉ូ** បើយើងទ្រាំនៅទីនេះតទៅទៀត ពិតជារស់មិនបានយូរទេ ។ ណាមួយជម្ងឺគ្រុនចាញ់ ណាមួយអត់បាយ ។ ខ្លួនអូននិងបងនៅសល់តែស្បែកនិងឆ្អឹង ។
- ចុះបងគិតចង់ទៅណា?



- បងចង់នាំអូនរត់ទៅនៅភូមិ **អូរស្រឡៅ** ព្រោះបងឮថាអោយតែនរណារត់ទៅដល់ភូមិនោះ ប្រធានភូមិទទួលឱ្យនៅ ។

ក្រោយពីបានប្តូរយោបល់គ្នាអស់ជាច្រើនថ្ងៃមក គេទាំងពីរនាក់ក៏ដាច់ចិត្តរត់ចេញពី **ភ្នំធិបតី** នៅពេលរាត្រីរនោចនៃដើមឆ្នាំ ១៩៧៧ ។ ក្រៅពី **សម-ប៊ុន** និងនាង **រ៉ូ** មានអ្នកថ្មីបីនាក់ទៀតរួមដំណើរទៅជាមួយគេទាំងពីរ ។ នៅកណ្តាលអធ្រាត្រ ទាំងប្រាំនាក់នាំគ្នាធ្វើដំណើរក្រោមពន្លឺផ្កាយ ។ គេសំដៅទៅភូមិអូរស្រឡៅដែលនៅចម្ងាយប្រហែល ២០គីឡូម៉ែត្រពីភ្នំធិបតី ។ ជាអកុសលនៅពេលដើរបានប្រហែលពីរគីឡូម៉ែត្រ ស្រាប់តែជួបរវូមវាក់និងកងឃាមល្បាតខ្មែរក្រហម ដែលរៀងរាល់យប់ពួកវានាំគ្នាចាំស្ទាក់អ្នកថ្មីដែលរត់ចេញពី **ភ្នំធិបតី** ។ គួរកត់សំគាល់ថា ជំនាន់នោះភូមិនិមួយៗមានការគ្រប់គ្រងប្លែកៗនិងខុសៗពីគ្នា ។ ប្រធានភូមិមានអំណាចលើសពីព្រះចៅអធិរាជក្រុងចិនទៅទៀត... ។

ពួកខ្មែរក្រហមបានបាញ់សង្ស្រកទៅលើអ្នកទាំងប្រាំ ។ នៅភាពអាសន្ននេះ **សម-ប៊ុន** និងប្រពន្ធរត់បែកៗគ្នាមិនដឹងទៅទិសណា ព្រោះរាត្រីនោះងងឹតចាក់ភ្នែកមិនយល់ ។ **សម-ប៊ុន** ចេះតែរត់ទៅមុខឥតឈប់ឈរ ហាក់ដូចជាគ្មាននឿយហត់ ។ ទីបំផុត

គេមកដល់ព្រៃស្ងប់ទ្រប់មួយ ។ គ្រាន់តែដាក់បង្គុយចុះ **សម-ប៊ុន** ក៏ដួលសន្លប់បាត់ស្មារតីទៅ ។

នៅពេលដឹងខ្លួនឡើងវិញ **សម-ប៊ុន** ឃើញព្រះអាទិត្យជ្រេបន្តិចទៅហើយ ។ ពោះកូរគ្រូកៗដោយសារឃ្លានបាយ **សម-ប៊ុន** ខំប្រវេរប្រវារក្រោកឈរ ស្រាប់តែក្រឡេកទៅឃើញភូមិ **អូរស្រឡៅ** នៅជិតបង្កើយ ។ រំពេចនោះគេមានកម្លាំងព្រឺស... ប៉ុន្តែលុះនឹកដល់ប្រពន្ធ **សម-ប៊ុន**ក៏រលំគ្រេងទៅលើដីវិញ ។ គេយំសោកសង្រេងនឹកថាប្រពន្ធគេមុខជាស្លាប់ក្រោមគ្រាប់កាំភ្លើងរបស់ខ្មែរប្រហម ។ មួយសន្ទុះក្រោយមក **សម-ប៊ុន** ក៏ខំប្រវេរប្រវារក្រោកដើរសំដៅចូលទៅក្នុងរោងបាយ ។ អ្នកភូមិម្នាក់ក៏ស្ទុះទៅហៅអ្នកទទួលខុសត្រូវ ។

បន្តិចក្រោយមក គេឃើញក្មេងស្រីម្នាក់រាងទាបទ្រនាប់ដើរចូលមកហើយសួរទៅ **សម-ប៊ុន** ថា :

- យីមិត្តឯងឈ្មោះអីហើយមកពីណាបានជាស្គមម្ល៉េះ?

- ខ្ញុំឈ្មោះ **ចូច** (**សម-ប៊ុន** ដូរឈ្មោះ) ។

ឮតែឈ្មោះ **ចូច** នារីនោះសើចយឹក ។

- យី! ឈ្មោះគរគោកមិនដាក់ទៅដាក់ឈ្មោះ **ចូច** ។

និយាយរួចនារីនោះសើចទៀតហើយបញ្ជាទៅមិត្តម្នាក់ :

- មិត្ត **ម្រេច** មិត្តឯងយកបាយឱ្យមិត្ត **ចូច** ហូបផង ។



មិត្ត **ម្រេច** លើកបាយនិងសម្លមួយចានធំមកដាក់ពីមុខមិត្ត **ចូច** ។ **សម-ប៊ុន** ឃើញបាយសម្លស្ទុះទៅត្របាក់មើលតែជ្រូកខ្មែរស៊ីលាមក ព្រោះឥតដែលបានហូបបាយយូរហើយ ។ នារីក្មេងចេះតែសម្លឹងមើលមិត្ត **ចូច** សើចញឹមៗរួចក៏ប្រាប់ទៅមិត្ត **ម្រេច** ។

- មិត្ត **ម្រេច** ឯងមើលរៀបចំកន្លែងឱ្យមិត្ត **ចូច** នៅផងចុះ ចាំខ្ញុំទៅប្រាប់ពុក ។

នៅពេលនារីនោះដើរចេញទៅមិត្ត **ម្រេច** និយាយទៅកាន់មិត្ត **ចូច** ។

- មិត្ត **ចូច** ឯងបានមកដល់ភូមិ **អូរស្រឡៅ** គឺសំណាងធំហើយព្រោះមិត្តនារី**ទាប**អម្បាញ់មិញចិត្តល្អណាស់ ។ នាងជាកូនប្រធានភូមិ ហើយក្តោបក្តាប់យុវជននិងយុវនារីទាំងអស់នៅក្នុងភូមិ។

**សម-ប៊ុន** មិនសូវយកចិត្តទុកដាក់នឹងស្តាប់មិត្ត **ម្រេច** ប៉ុន្មានទេ ព្រោះរវល់តែពមបាយ ។ លុះបាយរួចហើយមិត្ត **ម្រេច** ក៏នាំ **សម-ប៊ុន** ទៅសម្រាកនៅលើផ្ទះក្បឿងមួយយ៉ាងធំ... គឺជាផ្ទះសម្រាប់យុវជនប្រហែល ៣០នាក់សម្រាកនៅ ។ **សម-ប៊ុន** ដេកសម្រក់ទឹកភ្នែកព្រោះអាឡោះអាល័យប្រពន្ធ ។ នៅពេលព្រះអាទិត្យអស្តង្គត គេតែងតែសម្លឹងមើលទៅ**ភ្នំធិបតី** ហើយនឹកទៅដល់កំណាព្យកាព្យឃ្លោងមួយ :

***"មើលភ្នំធំធេងវែងវលឹក មើលទឹករលករលាមសាយ***
***មើលដីដីផុះវែងអន្ទាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី..."***

ក្រោយពីសម្រាកបានបីបួនថ្ងៃ **សម-ប៊ុន** ក៏ចេញធ្វើពលិកម្មដូចគេដូចឯង ។ **សម-ប៊ុន** សកម្មក្នុងការងារណាស់ជាហេតុធ្វើឱ្យពុក**ងៀន** ជាប្រធានភូមិនិងមិត្តនារីពេញចិត្តស្លុក ។ ដោយសារមានបាយហូប **សម-ប៊ុន** មានសាច់មានឈាមឡើងវិញ ។ គេបានក្លាយទៅជាយុវជនមួយរូបដ៏សង្ហា ដែលជាទីប៉ុនប៉ងនៃនារីគ្រប់រូបនៅក្នុងភូមិ ។ កាល **សម-ប៊ុន** មិនទាន់មកនៅភូមិអូរស្រឡៅ មានតែមិត្ត **ម្រេច** ទេដែលពូកែធ្វើការជាងយុវជនឯទៀត ។ តែរូបរាងមិត្ត **ម្រេច** មិនសង្ហាដូចមិត្ត **ចូច** ទេ... ។ មិត្ត **ម្រេច** បានស្នើនារី**ទាប**ធ្វើជាភរិយាម្តង ។ ពុក **ងៀន** ដែលជាឪពុកនាងឥតមានការយល់ទាស់ តែមិត្តនារី**ទាប**នៅស្ទាក់ស្ទើរមិនព្រមឆ្លើយថាព្រមឬមិនព្រម ។ លុះបានមិត្ត **ចូច** នៅក្បែរ នាងភ្លេចមិត្ត **ម្រេច** តែម្តង ។ យុវនារីនិងយុវជនតែងតែនាំគ្នាដៀមដាមឱ្យមិននារីទាបថា :

***"បានស្វាយ ណាយក្រូច***
***បានមិត្តចូច ភ្លេចមិត្តម្រេច"***



ថ្ងៃខែចេះតែកន្លងទៅ មិត្តនារី**ទាប**កាន់តែមានចិត្តទៅលើ **សម-ប៊ុន** ។ ទៅណាមកណានាងតែងតែហៅ **សម-ប៊ុន** ឱ្យទៅជាមួយ ។ **សម-ប៊ុន** យល់ចិត្តនាងណាស់ តែគេនៅអាឡោះអាល័យភរិយាគេនៅឡើយ ។ ម្យ៉ាងទៀត **សម-ប៊ុន** ភ័យខ្លាចខុសសីលធម៌ ចេះតែគេចពីនារីតូច ។ ថ្ងៃមួយនោះនៅពេលព្រលប់ **សម-ប៊ុន** ទៅមុជទឹកអណ្តូងស្រាប់តែជួបនារីតូចកំពុងមុជទឹកនៅទីនោះដែរ ។ នាងចងពុងបញ្ចេញសាច់ទ្រូងសម៉ដ្ឋខៃ ។ **សម-ប៊ុន** ងាកក្រោយបម្រុងត្រឡប់ទៅវិញស្រាប់តែឮមិត្តនារីតូចហៅ :

- មិត្ត**ចូច**ជួយដងទឹកឱ្យខ្ញុំមួយធុងសិន ។

**សម-ប៊ុន** ដើររាងភ័យៗទៅដងទឹកឱ្យនារីតូច ។

- មិត្តឯងស្រោចទឹកឱ្យខ្ញុំមក
- មិនកើតទេ! នារីតូច... ខ្ញុំខ្លាចខុសសីលធម៌ណាស់
- គ្មានខុសសីលធម៌អីទេ គ្រាន់តែស្រោចទឹកឱ្យខ្ញុំនោះ ។

**សម-ប៊ុន** រញ៊ីរញ៉េរខំស្រោចទឹកឱ្យនារីតូច ។ នារីតូចចាប់ដៃ**សម-ប៊ុន**ជាប់ហើយនិយាយថា :

- បងឯងកុំភ័យពុកខ្ញុំជាអង្គការគាត់មិនថាអីទេ ។

ថ្ងៃមួយមិត្តនារីទាបបានសារភាពនូវមនោសញ្ចេតនារបស់ខ្លួនប្រាប់ឪពុក ។ ពុក**ងៀន** យល់ចិត្តកូនស្រីក៏ហៅ **សម-ប៊ុន** មក

សួរ ។ **សម-ប៊ុន** មិនហ៊ានប្រកែកព្រោះយល់ថាប្រពន្ធស្លាប់ជិតមួយឆ្នាំមកហើយ ។ ដំណឹងនេះលេចឮពេញភូមិ ធ្វើឱ្យមិត្ត **ម្រេច** ដេកអន់ចិត្តសម្រក់ទឹកភ្នែកស្ដាយនារីតូច ។ ពុក**ងៀន** ប្រធានភូមិបម្រុងឱ្យការកូនក្នុងពេលឆាប់ៗខាងមុខ ។ មិត្តនារីតូច តាំងតែពីគេដឹងឮរឿងនេះគ្រប់ៗគ្នា មកក៏ខំបម្រើថ្នាក់ថ្នម **សម-ប៊ុន** ដោយឥតខ្មាសអៀន ។ ព្រឹកថ្ងៃមួយនោះពុក**ងៀន**បានចាត់**សម-ប៊ុន**ឱ្យទៅដឹកស្រូវពូជនៅឃុំ**អូរដំបង** ។ ឃុំនេះនៅមិនឆ្ងាយពីភូមិ**អូរស្រឡៅ**ប៉ុន្មានទេ ប៉ុន្តែចំពោះអ្នកថ្មីដែលគ្មានសិទ្ធិដើរពីភូមិមួយទៅភូមិមួយបាន...**អូរដំបង**ក៏ហាក់ដូចជានៅឆ្ងាយពី**អូរស្រឡៅ**រាប់ពាន់យោជន៍ប្រៀបបានប្រទេសខ្មែរនិងប្រទេសបារាំង ។ នៅពេល **សម-ប៊ុន** បររទេះចូលទៅក្នុងភូមិ ស្រាប់តែជួបវ៉ាក់អីនឹងក្មេងប្រុសម្នាក់ដែលរត់រួចពី**ភ្នំធិបតី**មកនៅភូមិ**អូរដំបង** ។ ឃើញ **សម-ប៊ុន** ក៏ស្ទុះទៅប្រាប់ **សម-ប៊ុន** ភ្លាម :

- បង**ប៊ុន**! បង**ប៊ុន**! ប្រពន្ធបងឯងនៅរស់ទេ ។ គាត់នៅឯរោងបាយឯណោះ

- ថាម៉េច! ថាម៉េច! ប្រពន្ធខ្ញុំនៅរស់!

- ពិតហើយ! ពិតហើយ!



**សម-ប៊ុន** រត់ទៅរោងបាយ ស្រាប់តែឃើញនាង **រ៉ូស្ដាលីន** កំពុងអង្គុយបេះបន្លែ ។ ប្រពន្ធឃើញប្ដីស្រាប់តែទួញង៉ោងផ្អើលអស់មនុស្សនៅក្នុងរោងបាយ ។ នាង**រ៉ូ**នៅយប់រត់ចេញពី**ភ្នំធិបតី**មិនបានស្លាប់ដូចការស្មានរបស់**សម-ប៊ុន**ទេ ។ នាងខំរត់ត្រដររហូតមកដល់ឃុំ**អូរដំបង** បាន**តាលី**ប្រធានឃុំទទួលឱ្យស្នាក់នៅ ។ នាងក៏យល់ថា **សម-ប៊ុន**ស្លាប់បាត់ទៅហើយដែរ ។ នៅក្នុងឃុំ**អូរដំបង**មានយុវជនជាច្រើនស្ដីដណ្ដឹងនាងតែនាងមិនព្រម ព្រោះមិនចង់បានប្ដីមួយជាពីរ ។ នាង**រ៉ូ**នាំ**សម-ប៊ុន**ទៅជួប**តាលី** ប្រធានឃុំ ។ **តាលី** ជួយអរនាង**រ៉ូ** គាត់ប្រាប់ថា បើ**សម-ប៊ុន**ចង់មករស់នៅឃុំ**អូរដំបង**ក៏បាន ឬមួយនាង**រ៉ូ**ទៅតាមប្ដីនៅភូមិ**អូរស្រឡៅ**ក៏បានស្រេចតែចិត្តទៅចុះ ។ **សម-ប៊ុន**អរផងភ័យផងព្រោះបញ្ហាមួយដ៏ស្មុគស្មាញបានចោទឡើង : គឺនារីតូច ។ មិត្ត**ចូច**រ៉ាយរ៉ាប់ប្រាប់រឿងទាំងអស់ដល់នាង**រ៉ូ** ។ នាងឥតមានខឹងសម្បារនិងប្ដីទេ ព្រោះកុំតែបាននារីតូចនិងឪពុកនាងជួយ**សម-ប៊ុន**ក៏មិនរស់ដែរ ។

- បើសិន (នាង**រ៉ូ**និយាយ) ស្រុកដូចពីដើម ខ្ញុំសុខចិត្តឱ្យបងឯងទទួលនាងតូចជាភរិយាទីពីរ ។

**សម-ប៊ុន**ត្រឡប់ទៅភូមិ**អូរស្រឡៅ**ទាំងមុខខ្មៅប៉ែនឹកថាជាគ្រោះថ្នាក់ដល់ជីវិតផងក៏មិនដឹងនៅក្នុងរឿងរសេមរសាមជាមួយមិត្ត

នារី**តូច**នោះ ។ នៅពេលបរទេះទៅដល់ភូមិ ក្រោយពីដាក់ទុកស្រូវពូជស្រួលបួលហើយ **សម-ប៊ុន**ដើរសំដៅទៅផ្ទះនារី**តូច** ។ ឃើញ**សម-ប៊ុន**ពីចម្ងាយមិត្តនារី**តូច**ខំស្ទុះមកទទួល ។

- បង**ចូច** ម្ដេចក៏មុខក្រៀមម្ល៉េះថ្ងៃនេះ?

**សម-ប៊ុន** សួរទៅនាងវិញ :

- តើពុក (**សម-ប៊ុន**ទម្លាប់ហៅពុក**ងឿន**ថាពុកៗតាំងពីមកដល់ភូមិ**អូរស្រឡៅ**ជាលើកដំបូងម្ល៉េះ) នៅផ្ទះឬទេ?

- បងឯងរកពុកធ្វើអី?

**សម-ប៊ុន**ឥតឆ្លើយ ស្ទុះឡើងជណ្ដើរ ។

មិត្តនារី**តូច**ប្លែកនិងអាកប្បកិរិយាមិត្ត**ចូច** ក៏ដើរទៅតាមក្រោយ ។ នៅពេលឡើងទៅដល់លើផ្ទះ ស្រាប់តែ**សម-ប៊ុន**លុតជង្គង់ថ្វាយបង្គំពុក**ងឿន**បីដង ។ មិត្តនារី**តូច**ទៅជាភ័ន្តភាំង ។ ចំណែកពុក**ងឿន**ក៏លែងយល់អ្វីទាំងអស់ ។

- ពុក (**សម-ប៊ុន**និយាយ) បើពុកឱ្យកូនស្លាប់កូនក៏ស្លាប់ បើឱ្យកូនរស់កូនក៏រស់...

- យីកូនឯង (ពុក**ងឿន** ទម្លាប់ហៅមិត្ត**ចូច** ថាកូន) មានរឿងអីហ្នឹង? ពុកឯណាទៅដាច់ចិត្តសម្លាប់កូន ព្រោះតែកន្លះខែទៀតឯងក្លាយទៅជាកូនប្រសាពុកហើយ!



- ពុក! កូនស្មានតែប្រពន្ធកូនស្លាប់ទៅហើយ ។ ឥឡូវនាងនៅរស់ទេ ខ្ញុំបានទៅជួបនាងនៅ**អូរដំបង** ។

ពុក**ងឿន**លែងមាត់ ចំណែកមិត្តនារី**តូច**យំស្បែបរត់ចូលបន្ទប់ ។ ពុក**ងឿន**សម្លឹងមើល**សម-ប៊ុន** ។ **សម-ប៊ុន**ភ័យស្ទើរលោះព្រលឹងចាំស្ដាប់ពុក**ងឿន** ។ ព្រោះសម្ដីគាត់បើចេញមកពិតជាមួយម៉ាត់ស្លាប់ មួយម៉ាត់រស់ ។

ពុក**ងឿន**ដកដង្ហើមធំបែបខ្វល់ខ្វាយក្នុងចិត្តណាស់ ព្រោះដំណឹងរៀបការមិត្ត**ចូច**និងនារី**ទាប**គេដឹងពេញភូមិទាំងអស់ហើយ ។ **សម-ប៊ុន**ឥតកម្រើកបត់ជើងក្រវៀនៗ ។ យូរណាស់ទើបគាត់និយាយ ។

- បើកូន**ចូច**ឯងជួបប្រពន្ធហើយ កូនឯងទៅនៅជាមួយនាងទៅចុះ!

គាត់និយាយរបៀបអាក់ៗ ចំណែកមិត្តនារី**តូច**កាន់តែខ្សឹកខ្សួលខ្លាំងឡើងៗ ។

**សម-ប៊ុន**ធូរទ្រូងខ្លាក ហើយថ្វាយបង្គំពុក**ងឿន**បីដងទៀតប្រៀបដូចគ្រហស្ថថ្វាយបង្គំលោក ។ **សម-ប៊ុន**ស្ទុះទៅលួងលោមនាងនារី**តូច** តែនាងឥតឆ្លើយពីតតែពីយំថែមទៀត ។

ក្រោយពី**សម-ប៊ុន**ចុះពីផ្ទះ ពុក**ងឿន**ទៅលួងលោមកូនថែមទៀត ។ ពុក**ងឿន**ស្រឡាញ់និងអាណិតនារី**តូច**ណាស់ ព្រោះនាង

កំព្រាម្ដាយតាំងពីតូច ។ គាត់ឥតមានយកប្រពន្ធទៀតទេ ព្រោះខ្លាចប្រពន្ធចុងធ្វើបាបកូនស្រីតែមួយរបស់គាត់ ។ បើតាមការសង្កេតរបស់អ្នកថ្មី ពុក**ងឿន**ប្រធានភូមិ**អូរស្រឡៅ** ដូចជាមិនក្រហមឆ្អិនឆ្អៅប៉ុន្មានទេ ។

– កូន**តូច**កុំយំអី! កូនកុំយំអី! អានេះវាមិនមែនគូ (ពុក**ងឿន**និយាយទៅកូនស្រី) ពុករៀបចំទុកដាក់ឯងឱ្យទៅមិត្ត**ម្រេច** ព្រោះវាក្មេងមានគំនិតមារយាទត្រឹមត្រូវដែរ ។

– ទេពុក! បើមិនបាបបង**ចូច**ជាគូកូនសុខចិត្តនៅព្រៅ!

ពុក**ងឿន** អាណិតកូនស្ទើររហែកបេះដូង គាត់លែងនិយាយតទៅទៀត ។

## ផ្លូវទៅរកការស្ងប់ស្ងាត់

***នត្ថិសន្តិបរំសុខំ*** *(គ្មានសេចក្ដីសុខឯណាក្រៅពីសេចក្ដីស្ងប់ឡើយ)*



**សម-ប៊ុន** ចេញពីភូមិ**អូរស្រឡៅ**ទៅ**អូរដំបង**នៅចុងឆ្នាំ ១៩៧៧ ។ គេមករស់នៅភូមិ**អូរស្រឡៅ**បានមួយឆ្នាំគត់ ។ នារីតូចនៅតែមិនអស់ចិត្តពី**សម-ប៊ុន** ។ នាងនៅតែស្រឡាញ់មិត្ត**ចូច** នៅតែទុកគេជាស្វាមី ព្រោះនាងយល់ព្រមធ្វើជាភរិយាគេរួចទៅហើយ ។ នារី**តូច**ពិតជាមេម៉ាយផ្លូវចិត្ត ។ នាងតែងតែឆ្លៀតឱកាសទៅលេងគ្រួសារ**សម-ប៊ុន**នៅ**អូរដំបង** ។ នាង**រ៉ូ**ស្រឡាញ់នារី**តូច**ណាស់ ។ នៅក្នុងចិត្ត**រ៉ូស្តាលីន** បើមិត្តនារីតូចសុំចែក**សម-ប៊ុន** នាងពិតជាយល់ព្រម ។

ថ្ងៃនិងខែចេះតែកន្លងទៅ ។ ពុក**ងឿន**មានជម្ងឺជាទម្ងន់ មិនយូរប៉ុន្មានគាត់ក៏ស្លាប់ចោលមិត្តនារី**តូច**ទៅ ។ នាង**តូច**នឹកកម្សត់ខ្លួនឯងជាខ្លាំង ។ ឪពុកក៏ស្លាប់សង្សារក៏រើសចំប្ដីគេទៀត ។

ថ្ងៃ ២៧ ធ្នូ ឆ្នាំ ១៩៧៨ ទ័ពយួនបានចូលមកលុកលុយប្រទេសកម្ពុជាពីទិសខាងកើតនិងខាងត្បូង ។ ស្វាយរៀង តាកែវ កំពត ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនៈគិរី ធ្លាក់ទៅក្នុងកណ្ដាប់ដៃយួន តែរយៈពេលមួយអាទិត្យប៉ុណោះ ។ យួនវាយយកប្រទេសខ្មែរស្រួលដូចបកចេក (c'était vraiment une promenade militaire)... ។ ពួកខ្មែរក្រហមឮតែយួនមកដល់ត្រង់ណា វារត់យកតែប្រាសអាយុ ។ អានេះពូកែតែយកខ្មែរទៅ

វាយនិងត្បូងចបទេ ។ ពួកវាខ្លាចយួនជាងខ្លាចខ្លាទៅទៀត ។ ដើមខែមករា ឆ្នាំ ១៩៧៩ ទើបយួនចូលមកដល់ខេត្តបាត់ដំបង ។ ពួក**អាពត**រត់ចូលព្រៃអស់ ។ ពួកអានេះក្រុងមិនចេះនៅទេចេះតែនៅក្នុងព្រៃមិនខុសពីសត្វសាហាវនោះឡើយ ។

អ្នកថ្មីដែលសេសសល់ពីស្លាប់នាំគ្នាត្រឡប់ទៅភ្នំពេញ ឬស្រុកកំណើតរបស់ខ្លួន ។ **សម-ប៊ុន** ឥតទាន់ទៅណាទេ ព្រោះប្រពន្ធត្រូវគ្រប់ខែនៅចុងខែមករា ឆ្នាំ ១៩៧៩ ។

នាង**រ៉ូ** ដោយនឹកអាណិតមិត្តនារី**តូច**កំព្រាឪពុក ក៏ស្នើឱ្យនាងរស់នៅឯ**អូរដំបង**វិញ គ្រាន់នឹងបានជាគ្នា ។ នាង**រ៉ូ**ក៏សម្រាលបានកូនប្រុសមួយថ្លោសទ្រលុច ។ **សម-ប៊ុន** ឱ្យឈ្មោះកូនថា **រដ្ឋា** ។ នារី**តូច**បម្រើនាង**រ៉ូ**ប្រៀបម្ដាយថៃកូន ឬប្អូនថែបង ។ អ្នកភូមិចេះតែនាំគ្នាខ្សឹបខ្សៀវថា នារី**តូច**ប្រហែលជាក្លាយទៅជាភរិយាទីពីររបស់ មិត្ត**ចូច**ទៅហើយក៏មិនដឹង ព្រោះទៅអណ្ដូងទឹក ទៅច្រូតតែពីរនាក់ ដូចប្ដីប្រពន្ធ ។ ចំណែកនាង**រ៉ូ**នៅផ្ទះមើលកូន ។ តាមពិត**សម-ប៊ុន**ឥតហ៊ានប៉ះពាល់នារី**តូច**ទេ គេទុកនាងដូចប្អូនបង្កើត ។ ផ្ទុយទៅវិញ នារី**តូច**នៅតែទុកបង**ចូច**គេជាស្វាមី ។



ខែឧសភា ឆ្នាំ ១៩៧៩ អ្នកភ្នំពេញជាច្រើននាំគ្នារត់ចេញពីប្រទេសខ្មែរសំដៅទៅប្រទេសសៀម ក្នុងគោលបំណងទៅប្រទេសទីបី មានប្រទេសអាមេរិក បារាំង អូស្ត្រាលី កាណាដា ជាដើម។ ពេលនោះមតិអន្តរជាតិចាប់ផ្អើលនិងរឿងខ្មែរ ។ ទម្រាំតែផ្អើលខ្មែរចង់ផុតពូជ ។ **សម-ប៊ុន** ដែលមានគោលបំណងរត់ចោលស្រុកជាយូរណាស់មកហើយនោះ ព្រោះគេមិនទុកចិត្តរបបកុម្មុយនិស្ត ក៏ស្នើយោបល់ប្រពន្ធថា :

- បើតាមបងស្ដាប់វិទ្យុសម្លេងសហរដ្ឋអាមេរិកផ្សាយជាភាសាខ្មែរ អ្នកដែលរត់ទៅដល់ប្រទេសសៀមច្បាស់ជាបានទៅប្រទេសទីបី ។ តើអូនយល់យ៉ាងណាដែរ?
- អូនតាមតែបងទេ (នាង**រ៉ូ**តប) បងជាជើងមុខ អូនជាជើងក្រោយ ។
- ចុះមិត្តនារី**តូច**? (**សម-ប៊ុន**សួរទៅប្រពន្ធ)
- ចាំអូនសួរនាងសិន

នាង**រ៉ូ**ក៏ហៅនាង**តូច**មកសួរ ។

- អូន**តូច!** បងទាំងពីរពិតជាធ្វើដំណើរទៅទិសខាងលិចហើយ ។
- បើបងទៅ (នារី**តូច**ឆ្លើយ) អូនក៏ទៅដែរ ។

- ខ្ញុំសុខចិត្តស្លាប់រស់ជាមួយបងទាំងពីរ ។ បើអូននៅក្នុងស្រុកនេះតទៅទៀតក៏ឥតន័យ ព្រោះឪពុកម្ដាយស្លាប់ចោលអស់ទៅហើយ... ។

ខែឧសភា ១៩៧៩ **សម-ប៊ុន**និងភរិយា ព្រមទាំងនារី**តូច** បានមកដល់ជំរំ **ណងចាន់** នៅក្នុងប្រទេសសៀម ។ អ្នកភ្នំពេញជាច្រើនរយនាក់ក៏បានមកដល់ទីនោះដែរ ។ នាង**រ៉ូ**រឹងដើរងជើងគួរសមហើយ ព្រោះថា **រដ្ឋា**អាយុបាន ៦ខែហើយ ។

ល្ងាចមួយនោះ **សម-ប៊ុន**និងនារី**ទាប**នាំគ្នាទៅដងទឹកនៅឯស្ទឹងមួយចម្ងាយប្រហែល ១០០ម៉ែត្រពីជំរំ ។ ថ្ងៃទើបតែនឹងលិចសោះតែងងឹតមើលមិនចង់ឃើញអ្វីៗទាំងអស់នៅក្បែរខ្លួន ។

នៅពេលនារីតូចចុះទៅក្នុងស្ទឹង ស្រាប់តែក្រឡាច់ជើងរកដួល ។ **សម-ប៊ុន**រហ័សដូចឆ្មាស្ទុះទៅទ្រនាង តែមិនដឹងជាចៃដន្យអីស្រាប់តែខ្លួននារី**តូច**ទាំងមូលធ្លាក់មកក្នុងដៃគេទាំងពីរ ។ ដងខ្លួននាងឡើងទន់ល្វក់ ។ **សម-ប៊ុន**ភ័យលោះព្រលឹង ព្រោះស្មានតែនាងខ្យល់គ ។ គេបីនាងសំដៅទៅក្រោមដើមឈើមួយយ៉ាងធំបម្រុងគក់ច្របាច់ឱ្យនាង ។ ស្រាប់តែដៃទាំងគូរបស់នារីទាបឱបក**សម-ប៊ុន**ជាប់ស្អិតជាងតឹកកែឱបកមនុស្សទៅទៀត ។



- បង**ចូច** (នាងនិយាយរបៀបដង្ហក់) អូនអត់ទ្រាំតទៅទៀតលែងបានហើយ ។ អូនសុខចិត្តធ្វើប្រពន្ធចុងរបស់បង ឱ្យតែអូនបាននៅជិតបង ។

ព្រួញកាមទេពបានបាញ់គេទាំងពីរនាក់ជាប់ឆ្អឹង មិនខុសពីចំណិតសាច់គោអាំងនៅក្នុងចង្កាក់នោះឡើយ ។ **សម-ប៊ុន**បីនារីតូចសំដៅគុម្ពោតព្រៃមួយ ។ សូរតែសម្លេងព្រួសប្រាស់! ព្រួសប្រាស់! រួចមកស្រាប់តែបាត់ស្ងាត់សូន្យឈឹងទៅហោង ។

មួយម៉ោងក្រោយមកទើប **សម-ប៊ុន** និងនារី**តូច** មកដល់ជំរំ ។

- ម៉េចក៏យូរម៉្លេះ? នាង**រ៉ូ**សួរ**សម-ប៊ុន** ។

ភ្លាមនោះនារី**តូច**ស្ទុះទៅបត់ជើងក្បែរនាង**រ៉ូ** ។

- បង**រ៉ូ**អូនសុំខមាទោស!

- យី! ទោសពៃរ៍អីអូនតូច?

- អូនក្បត់បង... អូនស្រឡាញ់បង**ចូច!**

នាង**រ៉ូ**យល់ស្ថានការណ៍ ហើយឆ្លើយយ៉ាងរបៀបវាហ៊ឺថា :

- ចុះវាមានទៅទាស់ខុសអី ។ ខ្មែរក្រហមរលាយបាត់ទៅហើយ ។ ចំណែកឯសីលធម៌ទីបី បួនទីបួនក៏វារលាយទៅដែរ ។

បងយល់ចិត្តអូនឯងយូរយារណាស់មកហើយ ។ បងសុខចិត្តចែកអូនឯងកុំភ័យ

នារី**ទាប** ស្ទុះទៅឱបនាង**រ៉ូ**យំអណ្ដឺតអណ្ដកដោយសេចក្ដីសប្បាយ ។

មួយថ្ងៃក្រោយមក **សម-ប៊ុន**ឮដំណឹងថាឪពុកនៅរស់ ហើយសព្វថ្ងៃសម្រាកនៅឯភូមិ **អូរក្រសាំង** មិនឆ្ងាយប៉ុន្មានពីទល់ដែនសៀមទេ ។ ពីភូមិ**អូរក្រសាំង** មកជំរំ**ណងចាន់** បើអ្នកដើរលឿនតែកន្លះថ្ងៃមកដល់ហើយ ។ **សម-ប៊ុន** លាប្រពន្ធទាំងពីរទៅរកឪពុកម្ដាយ ។ គេខំដើរផងរត់ផងព្រោះប្រញាប់មកវិញ មិនហ៊ានទុកប្រពន្ធកូនចោលតែឯង ។

ស្អែកឡើងពេលថ្ងៃត្រង់ **សម-ប៊ុន** ក៏មកដល់ជំរំ**ណងចាន់**វិញ ។ គេមកតែម្នាក់ឯងឥតមានឪពុកម្ដាយមកជាមួយទេ ។ ដំណឹងដែលថាឪពុកគេមកដល់ភូមិ**អូរក្រសាំង**នោះជាដំណឹងមិនពិត ។

សោកនាដកម្មមួយដែលគេមិនស្មានដល់ : ជំរំ**ណងចាន់**ស្ងាត់ជ្រងំ ។ មនុស្សម្នាមិនដឹងទៅណាអស់ ។ **សម-ប៊ុន**ស្ទុះទៅមើលជម្រករបស់ខ្លួន គ្មានឃើញអ្វីឡើយក្រៅពីឆ្នាំងបាយមួយនៅលើចង្ក្រាន ។ ភ្លើងឆេះហុយៗនៅឡើយមានន័យថាប្រពន្ធគេទើបនឹងចាកចេញពីជំរំនេះថ្មីៗនៅឡើយ ។ **សម-ប៊ុន**គិតអ្វីលែងឃើញ



ដំណើរទ្រេតទ្រោតដូចមនុស្សស្រវឹងកញ្ឆា ។ **សម-ប៊ុន**អង្គុយសំកុកទើបឃើញអ្នកភៀសខ្លួនខ្មែរមកដល់ជាបន្តបន្ទាប់ទៀត ។ ជាមួយគ្នានោះដែរ ពួកស្បែកសជាច្រើននាក់មកដល់ជំរំ**ណងចាន់**ដែរ ។ ពួកស្បែកសទាំងនោះ ខ្លះជាបុគ្គលិកខាងកាកបាទក្រហមអន្តរជាតិ (Croix Rouge Internationale) ខ្លះជាបុគ្គលិកខាងអង្គការជនភៀសខ្លួន (Haut Commissariat pour les réfugiés) ។ ពួកនេះមកដល់ភ្លាមក៏ហៅអ្នកភៀសខ្លួនឱ្យឡើងឡានយ៉ាងប្រញាប់ ហាក់ដូចជាខ្លាចមានព្រឹត្តិការណ៍អ្វីមួយកើតឡើង ។

**សម-ប៊ុន**ក៏ឡើងឡាននឹងគេរបៀបមនុស្សឡីកី មនុស្សឥតវិញ្ញាណ ។ ឡានធំៗបួនប្រាំគ្រឿងបានដឹកជញ្ជូនអ្នកភៀសខ្លួនខ្មែរមកដល់**អារញ្ញប្រាថេត** (Aranyaprathet) ។ មកដល់**អារញ្ញប្រាថេត** ទើបគេដឹងថាជនភៀសខ្លួនខ្មែរនៅជំរំ**ណងចាន់** បានត្រូវសៀមដឹកទៅទម្លាក់ចោលនៅភ្នំ**ដងរែក** ក្រោយពីបានដឹករួចម្ដងហើយទៅទម្លាក់ចោលនៅភ្នំ**ខៀវ**ឱ្យខ្មែរក្រហមសម្លាប់ចោលអស់ជាច្រើនឡាន...។ អ្នកធ្លាក់ភ្នំ**ដងរែក**ក៏ស្លាប់មិនស្មើរ ព្រោះត្រូវដើរឆ្លងកាត់ចំការមីន (Champ de mines) ។ ព្រឹត្តិការណ៍ដ៏ខ្លោចផ្សានេះ បានកើតឡើងនៅខែមិថុនា ឆ្នាំ ១៩៧៩ ។

ឱ! ខ្មែរយើងអើយ... ម្ដេចក៏អភ័ព្វម្ល៉េះ? ខ្មែរក្រហមក៏សម្លាប់ យួនក៏សម្លាប់ សៀមក៏សម្លាប់ ។

ដោយហេតុខ្លាចសៀមដឹកជនភៀសខ្លួនខ្មែរទៅសម្លាប់ចោលទៀត ទើបពួកអង្គការសហប្រជាជាតិខាងផ្នែកជនភៀសខ្លួនខំប្រឹងមកដឹកជញ្ជូនជនភៀសខ្លួនខ្មែរឱ្យទៅនៅជំរំ**អារញ្ញប្រាថេត** ។ ក្នុងចំណោមជនភៀសខ្លួនខ្មែរទាំងនោះ **សម-ប៊ុន**ស្គាល់គ្រួសារខ្មែរម្នាក់ដែលធ្លាប់ធ្វើពេទ្យនៅភ្នំពេញ គឺគ្រួសារលោក **វ៉ន** ។ គ្រួសារលោក **វ៉ន** មានគ្នាប្រាំនាក់ គឺប្រពន្ធនិងកូនជំទង់ពីរនាក់ និងក្មួយស្រីម្នាក់ឈ្មោះ **បុប្ផឆើត** ។ រឿងសោកនាកម្មរបស់**សម-ប៊ុន** គ្រួសារលោក**វ៉ន**ដឹងទាំងអស់ ។

ប្រពន្ធគាត់ក្ដី ខ្លួនគាត់ក្ដី ជាពិសេសនាង**ឆើត** តែងតែជួយលួងលោម**សម-ប៊ុន**កុំឱ្យកើតទុក្ខពេក ព្រោះមនុស្សយើងតែងកើតឡើងហើយតែងតែស្លាប់ទៅវិញ នេះជាច្បាប់ធម្មជាតិទេ ។ **បុប្ផឆើត** អាយុប្រហែល ២៥ឆ្នាំទេ ។ នាងមានរូបរាងខ្ពស់ស្រឡះ សម្បុរស្រស់ល្អឆើតឆាយដាច់នាង**រ៉ូស្គាលីន**ទៅទៀត ។ ភ្នែកនាងធំៗ ដូចភ្នែកមាន់ព្រៃជាស្រីដេញប្រុស ។ កាលនៅជាមួយខ្មែរក្រហម អង្គការដ៏មហិមាបានបង្ខំនាងឱ្យការជាមួយខ្មែរក្រហមដាច់ជើងម្នាក់ ។ យោធាពិការជាវិរៈបុរសរបស់ខ្មែរក្រហម បើគេសុំអីអង្គការត្រូវតែបំពេញចិត្តគេ ។ នៅពេលផ្សំដំណេកអង្គការត្រូវការជំនួយពីយោធាពីរនាក់ជួយចាប់ដៃចាប់ជើងនាង**ឆើត** ដើម្បីឱ្យវិរៈបុរសគេឡើងទៅគៀងទាងឋានលើ ។ បន្ទាប់ពីផ្សំដំណេករួច នាង**ឆើត**លេបគ្រាប់ស្លែងសម្លាប់ខ្លួនឯងតែវាមិនស្លាប់ ។ ក្រោយមកពេលយួនចូលស្រុកនាងក៏ដាក់មេផាយមកស្រុកសៀមជាមួយនឹងឪពុកមាតែម្ដង ។ មកនៅក្នុងជំរំ**អារញ្ញប្រាថេត**បានមួយអាទិត្យ បារាំងយកជនភៀសខ្លួនខ្មែរមួយយន្តហោះមកប្រទេសបារាំង ក្នុងចំណោមនោះមាន **សម-ប៊ុន** និងគ្រួសារលោក **វ៉ន** ដែរ ។ ម្ដងនេះ **សម-ប៊ុន**ជឿជាក់ថាប្រពន្ធកូនគេពិតជាស្លាប់ ។ **សម-ប៊ុន**ឱ្យតែនឹកដល់គ្រួសារក៏ស្រក់ទឹកភ្នែកច្រោក ។ គេដូចជាឡប់សតិនឹកគិតអ្វីៗលែងឃើញតែម្ដង ។ ជួនកាលច្រឡំនាង**ឆើត**ស្មានតែនាង**រ៉ូ** ឬក៏មិត្តនារី**តូច** ។ **បុប្ផឆើត**យកចិត្តទុកដាក់នឹង**សម-ប៊ុន**ណាស់ នៅក្នុងជំរំក៏ដូចជានៅក្នុងយន្តហោះ ។

**សម-ប៊ុន** បានមកដល់ប្រទេសបារាំង នៅខែកក្កដា ឆ្នាំ ១៩៧៩ ចំរដូវក្ដៅតែម្ដង ។ ជនភៀសខ្លួនខ្មែរទាំងអស់ប្រហែល ២០ គ្រួសារបានមកដល់មជ្ឈមណ្ឌលទទួលជនភៀសខ្លួន**ក្រេតី** (Créteil) ក្បែរទីក្រុងប៉ារីស៍។ ក្រៅពីខ្មែរ គេឃើញមានជនភៀសខ្លួនផ្សេងទៀតដូចជាអាហ្វ្រិកាំង ចាម តែពួកនេះមិនច្រើនដូចខ្មែរយើងទេ។

ជនភៀសខ្លួនត្រូវនៅ៦ខែក្នុងមជ្ឈមណ្ឌលដើម្បីរៀនភាសាបារាំង ។ កន្លងមកបានបីបួនខែ **សម-ប៊ុន**មានការស្រោកស្រាន្តជាច្រើនខាងផ្លូវចិត្ត ។ **បុប្ផឆើត** ដោយត្រូវម្ហូបម្ហារាល់ថ្ងៃក៏បែកសាច់កំភើៗ ។ នាងកៀក**សម-ប៊ុន**ជារៀងរាល់ថ្ងៃ ទោះជាពេលនៅរៀនក៏ដូចជាពេលបាយ ជាពិសេសពេលចេញដើរលេងទៅក្រៅម្ដងៗ ។ តែ**សម-ប៊ុន**ដូចជាគ្មានចិត្តទៅលើនាងទេ ព្រោះអារម្មណ៍របស់គេនៅតែជាប់ជំពាក់ទៅលើកូនប្រពន្ធនិងនារី**តូច** ។ ថ្ងៃមួយនោះ **សម-ប៊ុន**ធ្លាក់ខ្លួនឈឺ ហើយដេកដណ្ដប់ភួយញាក់ទទ្រើតនៅក្នុងបន្ទប់ ។ សីតុណ្ហភាពក្នុងខ្លួនគេឡើងដល់ ៤០អង្សា ។ គេមមើមមាយឃើញតែកូន... រួចមកនាង**រ៉ូ** បន្ទាប់មកទៀតនារី**ទាប** ។

- អូន**រ៉ូ** (**សម-ប៊ុន**មមើហៅប្រពន្ធ) អូន**ទាប**បងរងាណាស់! សង្កត់ពីលើមក!

**សម-ប៊ុន**ហាក់ដូចជាឮសម្លេងប្រពន្ធឆ្លើយនៅនឹងត្រចៀក...

- អូនសង្កត់ហើយ... បងអន់រងាទេ?

- អន់បន្តិចហើយ (**សម-ប៊ុន**ឆ្លើយខ្សាវៗ)

នៅពាក់កណ្ដាលអធ្រាត្រ **សម-ប៊ុន** ដូចជាធូរស្វាងបន្តិច តែនៅតែមិនទាន់ដឹងខ្លួន ។ គេស្រវាឱបនាង**រ៉ូ**នៅក្នុងសុបិន ។ គេរឹតប្រពន្ធគេខ្លាំងឡើងៗ ដូចពស់ថ្លាន់រឹតសត្វឈ្លូសដែលចាប់បានចំណី ។ ព្រលឹមស្រាងៗ **សម-ប៊ុន**ដឹងខ្លួនស្រាប់តែប៉ៃមាននាង**រ៉ូ**ឯណា គឺ**បុប្ផឆើត**សោះ ។ នាងកំពុងតែនៅក្នុងរង្វង់ដៃដ៏ធំរបស់**សម-ប៊ុន** ។



- ឱបអូនឱ្យខ្លាំងមកបង**សម-ប៊ុន** អូនសុខណាស់ សប្បាយណាស់ នៅក្នុងរង្វង់ដៃបង ។

**សម-ប៊ុន**ភ្ញាក់ក្រោកសើងមម៉ើង ។ **បុប្ផឆើត** ចាប់ផ្ដួលគេឱ្យដេកទៅលើពូកវិញ ។

- សម្រាកទៀតទៅបង បងនៅខ្សោយណាស់ ។

នៅពេលរៀបចេញពីមជ្ឈដ្ឋានទទួលជនភៀសខ្លួនលោក **វ៉ៃន** ក៏រៀបចំសែនព្រេនបន្តិចបន្តួចឱ្យ **បុប្ផឆើត** និង **សម-ប៊ុន** ។ គេទាំងពីរនាក់ក៏នាំគ្នាមកជួលផ្ទះនៅឯប៉ារីស៍ទី១៣ (Paris 13ème)...

ជាងមួយឆ្នាំក្រោយមក គឺនៅខែធ្នូ ឆ្នាំ ១៩៨០ **សម-ប៊ុន** បានទទួលសំបុត្រមួយដែលផ្ញើមកពីប្រទេសសៀម ហើយដែលមានសេចក្ដីដូចតទៅ :

*ខៅអ៊ីដាង ថ្ងៃទី ១៧ ធ្នូ ឆ្នាំ១៩៨០*

*មកដល់បង **សម-ប៊ុន***

*បង! នៅពេលដែលបងបានអានសំបុត្រនេះ អូននិងវដ្ដាបានត្រឡប់ទៅស្រុកខ្មែរវិញហើយ ។ អូននិងកូនបានមកដល់ជំរំ**ខៅអ៊ីដាង**នៅខែឧសភា*

*ឆ្នាំ ១៩៨០ រង់ចាំបង ព្រោះអូនជឿថាបងពិតជានៅរស់ ។ តែព្រហ្មលិខិតកំណាចណាស់ ។ អូនបានទទួលដំណឹងពីខ្មែរម្នាក់ដែលមកពីប្រទេសបារាំង ហើយដែលនៅរស់នៅប៉ារីសទី១៣ ក្បែរបងនោះដែរ ថាបងមានប្រពន្ធទៀតហើយ ហើយប្រពន្ធបងមានគភ៌ជិតកើតកូនទៅទៀត ។ មិនគួរបងដាច់បែកចិត្តពីខ្ញុំ ពីកូន និងអូន* ***តូច****សោះ ។ ខ្ញុំសូមជំរាបបងថា កាលបងត្រឡប់ទៅស្រុកខ្មែររកឪពុកម្តាយបងនោះ ពួកទាហានសៀមបានមកចាប់ជនភៀសខ្លួនខ្មែរទៅទម្លាក់នៅឯភ្នំ* ***ដងរែក*** *។ អូនពរកូននូវដៃ អូនតូចស្ពាយថង់អង្ករដើរពីមុខខ្ញុំ ។ នៅពេលសម្រាកដណ្តាំបាយ អូន* ***តូច****ទៅរកឧស ស្រាប់តែពេលនោះឮសូរសម្លេងមីនផ្ទុះឡើងយ៉ាងខ្លាំង ។ អូនស្ទុះទៅតាមអូនតូច ឃើញនាងដួលស្របាបនៅដីឈាមប្រឡាក់ពេញមុខមាត់ ។ អូន* ***តូច****ខំនិយាយមកកាន់ខ្ញុំថា :* ***"បងរ៉ូ សូមបងថែរក្សាប្តីយើងឱ្យបានល្អផង អូនមិនបានជួបគាត់ទៀតទេ"*** *។ និយាយបានតែប៉ុណ្ណឹងអូន* ***តូច****ក៏ដាច់ដង្ហើមទៅ ។*

*បង* ***សម-ប៊ុន*** *នៅពេលដែលម្តាយនិងប្អូនរបស់អូនស្លាប់ចោលទៅ បងបានយកធម៌ព្រះមកពន្យល់អូន អូននៅចាំមិនភ្លេច :* ***"សព្វេ ហិមេ វិនាភាវា*** *= សព្វសត្វទាំងឡាយ តែងតែមានការព្រាត់ប្រាស់ ចាកចោលរបស់ជាទីស្រឡាញ់.. ព្រោះថាមនុស្សសត្វទាំងឡាយមិនអាចនៅជួបជុំគ្នាឱ្យអស់ទាំងកប្ប ទាំងកល្បបានឡើយ" ។*

*ឥឡូវនេះវាពិតដូចធម៌ព្រះមែន ។ អូនសូមលាបងត្រឹមហ្នឹងហើយ សូមបងរស់នៅឱ្យបានសុខជាមួយភរិយាថ្មី ។*

*ហត្ថលេខា* ***រ៉ូស្នាលីន***



ក្រោយពីអានសំបុត្រនេះហើយ **សម-ប៊ុន**វិលមុខជ្រប់រកគិតអ្វីលែងយល់ ។ គឺជាខ្យល់ព្យុះកំណាចមួយ ដែលកំពុងតែបក់បោកនៅក្នុងខួរក្បាលរបស់គេហើយ ។

វិប្បដិសារី! វិប្បដិសារីកំពុងស្តីបន្ទោសគេហើយ ។ ផ្លូវសុខផ្លូវស្ងប់! តើឯងនៅទីណា?

ក្រោយមក នៅក្នុងវត្តមួយឯប្រទេសបារាំង គេឃើញលោកសង្ឃមួយអស់អង្គយភាវនាធម៌នៅមុខព្រះពុទ្ធរូប : ***"នត្ថិសន្តិ បរំ សុខំ១១*** *= គ្មានសេចក្តីសុខឯណាក្រៅពីសេចក្តីស្ងប់ឡើយ១១"* ។

ម្តងណោះ **សម-ប៊ុន** លែងភ្លេចព្រះហើយ ព្រោះមានតែព្រះអង្គទេ ទើបគេអាចរកការស្ងប់ឃើញ ។៕

# មេម៉ាយពីរឃើប

អ្នក **ពេជ** ជាបុត្រទោលនៃគ្រួសារលោកចាងហ្វាងសាលាដំបូង**ឈិន** ។ អ្នកស្រី **ឈិន** ស្រឡាញ់កូនជាងកែវភ្នែក ហើយថ្នាក់ថ្នមអ្នក**ពេជ**ជាងកែវចរណៃ ។ គ្រួសារនេះរស់នៅក្នុងភូមិគ្រឹះមួយដ៏ធំស្កឹមស្កៃ ដែលស្ថិតនៅលើដងវុក្ខវិថី **នរោត្តម** មិនឆ្ងាយប៉ុន្មានពីរោងកុន **ស៊ីណេលុច** ឡើយ ។ អ្នកស្រី**ឈិន**ថ្នាក់ថ្នមកូនសឹងមិនហ៊ានហៅចំឈ្មោះ ។ ជួនកាលគាត់ហៅអ្នក ជួនកាលគាត់ហៅអ្នក**ពេជ** ។ អ្នក**ពេជ**ជាកូនលុះដោយដំបូន្មានដោយបទល្អគ្រប់ជប់ដូចសំពត់ក្នុងផ្គត់ ។ អ្នក**ពេជ**ជានិស្សិតនៅមហាវិទ្យាល័យពេទ្យ ។ មកពីសាលាចូលបន្ទប់ ចេញពីក្នុងបន្ទប់ទៅសាលាទៀងទាត់ពេលវេលាល្អណាស់មិនដែលធ្វើឱ្យម្ដាយពិបាកចិត្តទេ ។ នៅពេលបាយ

បើមានត្រីអាំង លោកស្រី**ឈិន**បេះត្រីឱ្យកូន ខ្លាចឆ្អឹងស្លាក់កអ្នក**ពេជ** ។ ចំណែកលោក**ឈិន**វិញ អ្នកស្រីពុំសូវរវីរវល់ទេ ជាហេតុធ្វើឱ្យលោកចាងហ្វាងច្រណែននិងកូនមួយដងមួយកាល ។ ពេលខ្លះលោកស្រី**ឈិន**អង្គុយគិតម្នាក់ឯង តើរកគូស្រករបៀបណាទៅឱ្យស័ក្តិសមនឹងអ្នក**ពេជ** បើមានទាំងចំណេះមានទាំងទ្រព្យសម្បត្តិ ។

## មេម៉ាយក្រហម

នៅឆ្នាំ (១៩៧៥) ភ្នំពេញធ្លាក់ អ្នក**ពេជ**ជានិស្សិតឆ្នាំទី ៤ នៃវិទ្យាល័យពេទ្យ ។ ពេលចេញដំណើរពីភ្នំពេញដូចគេឯង អ្នកស្រី**ឈិន**ជេរប្រទេចផ្តាសាខ្មែរក្រហមមិនស្ងាង ព្រោះទ្រព្យសម្បត្តិដែលរកបានមកពីការស៊ីសំណូករបស់ប្តីគាត់ត្រូវរលាយអស់នៅពេលនេះតែម្តង ។ ដើរមកដល់ជ្រោយអំពិល លោក**ឈិន**ក៏ចូលទៅបម្រើអង្គការឯភ្នំពេញវិញ ព្រោះឃើញប្រកាសអង្គការបិទនៅលើដើមគអំពាវនាវរកអតីតរដ្ឋការឱ្យទៅជួយធ្វើការ *"កសាង"* ស្រុកឡើងវិញ ។ លោក**ឈិន**ទៅគ្មានថ្ងៃត្រឡប់ ។ ចំណែក**ពេជ** និងម្តាយក៏ធ្វើដំណើរតទៅមុខទៀតពីរនាក់ម៉ែកូន លេចព្រៃចូលវាល



លេចវាលចូលព្រៃ រហូតដល់ភូមិ**ជ័យសម្បត្តិ** ក្នុងស្រុក**តំបែរ** ខេត្តកំពង់ចាម ។

ភូមិ**ជ័យសម្បត្តិ** ស្ថិតនៅកណ្តាលវាលស្រែដ៏ល្វឹងល្វើយ មានផ្ទះប្រហែល ៧០ខ្នង ។ ផ្ទះមួយភាគធំសង់អំពីឈើ ដំបូលប្រក់ក្បឿងឬស្បូវ ។ មួយភាគទៀតសង់អំពីឫស្សី ដំបូលប្រក់ស្លឹកខេមា ។ មិនឆ្ងាយប៉ុន្មានពីភូមិគឺព្រៃឈើដ៏សមសាន្ត ដែលអ្នកថ្មីចោលឆ្អឹងនៅទីនោះមិនដឹងប៉ុន្មានរយនាក់ឡើយ ។

ភូមិ**ជ័យសម្បត្តិ** ទទួលប្រជាជនថ្មីប្រហែល ១០០គ្រួសារមានតាំងពីចាម-ចិន-ខ្មែរ ។ គ្រួសារខ្លះរស់នៅក្នុងរោងឫស្សី ខ្លះក្នុងខ្ទម ដែលសង់ឱ្យតែបាននៅ ។ គ្រួសារអ្នក**ពេជ**មានសំណាងជាងគេ ព្រោះបានសំណាក់នៅក្រោមផ្ទះក្បឿងរបស់ប្រជាជនចាស់មួយគ្រួសារ ។ គ្រួសារនេះមានតែប្តីប្រពន្ធ ឥតមានកូនចៅនឹងគេទេ ។ ការដែលគួរឱ្យកត់សំគាល់គឺប្តីមានរូបអាក្រក់ ខ្មៅក្រញេះតូចទាបមិនស័ក្តិសមនឹងប្រពន្ធ ថ្វីត្បិតតែអ្នកស្រែតែមានរូបសម្បត្តិល្អឆើតឆាយ ហើយនៅក្មេងល្អក់នៅឡើយ គឺជាបុប្ផាមួយទងលាក់ខ្លួននៅស្រុកស្រែ ។ ប្តីឈ្មោះ **ទុន** ប្រពន្ធឈ្មោះនាង **តុម** ត្រូវ

ជាប្អូនបង្កើតរបស់ប្រធានភូមិ**ជ័យសម្បត្តិ** ។ ប្ដីអាយុប្រហែល ៣៦ ឆ្នាំ ប្រពន្ធខ្ទង់ ២៧ ឬ ២៨ តែសាច់នៅខ្ចីល្វក់ ។

បើតាមអ្នក**ពេជ** ប្ដីប្រពន្ធពីរនាក់នេះមិនដេកនៅជាមួយគ្នាទេ ប្រពន្ធដេកក្នុងបន្ទប់ប្ដីដេកនៅត្រង់មាត់ទ្វារ ។ ប្ដីខ្លាចប្រពន្ធដូចខ្លា ។ បើតាមពាក្យរអេចរអូចតាំងពីការ ១០ឆ្នាំមក ប្ដីបានតែម្ដងគត់ គឺបានដោយវេទនាបំផុតនៅពេលយប់ផ្សំដំណេក ។ ក្រោយៗមកឱ្យតែប្ដីវារគើមៗមកក្បែរ នារី**តុម**គ្រហឹមដេញមិត្ត**ទុន**ឱ្យទៅដេកនៅមាត់ទ្វារវិញដដែល ។ គួរឱ្យវេទនាណាស់មិត្ត**ទុន**អើយ!!....

អ្នកភូមិនិយាយថា កាលពីសង្គមឪពុកម្ដាយមិត្ត**ទុន** មានដីស្រែចំការច្រើនណាស់ ហេតុដូចនេះហើយទើបឪពុកម្ដាយមិត្តនារី**តុម**សុខចិត្តលើកកូនក្រមុំឱ្យទៅមិត្ត**ទុន** ។ អ្នក**ពេជ** និងម្ដាយដេកនៅក្រោមផ្ទះនារី**តុម**ជិតមួយឆ្នាំហើយ ។ ម្ដាយអ្នក**ពេជ**ដេកសម្រក់ទឹកភ្នែករាល់យប់ ព្រោះណាមួយនឹកអាណិតកូនកំលោះមិនសមមកធ្លាក់ខ្លួនដេកហិតភក់ជ្រាំក្រោមផ្ទះដ៏កន្ទ្របនេះសោះ ។

ក្នុងរយៈពេលមួយឆ្នាំ អ្នក**ពេជ**ត្រូវមេក្រុមចាត់តាំងថែរក្សាក្របីមួយនឹមរបស់មិត្ត**ទុន** ។ នៅភូមិ**ជ័យសម្បត្តិ**ជំនាន់នោះ អ្នកចាស់លែងចង់មើលគោក្របី ឬភ្ជួររាស់អស់ហើយ ពីព្រោះបានអ្នកថ្មីទៅជំនួស ។



ព្រលឹមឡើង អ្នក**ពេជ**ដឹកក្របីទៅភ្ជួររាស់នៅឯស្រែរួចហើយត្រូវនៅមើលវាឱ្យស៊ីស្មៅទាល់តែថ្ងៃលិចទើបត្រឡប់មកផ្ទះ ។ រៀងរាល់ព្រឹកមុនពេលទៅស្រែ មិត្តនារី**តុម**ខ្ចប់បាយនឹងស្លឹកចេកមួយកញ្ចប់ទុកឱ្យអ្នក**ពេជ** ។ **តុម** ជានារីបដិវត្តន៍ដ៏មហិមា ទិតៀននិងដៀលត្មះអ្នកភ្នំពេញគ្មានស្រាកស្រាន្ត ។ ធម្មតាមានតែក្មេងទេដែលប្រជាជនចាស់ឱ្យមើលគោក្របី ក្រោយពីភ្ជួររាស់រួច ។ ចំពោះអ្នក**ពេជ** គឺសំណាងធំហើយ ដែលបានឃ្វាលក្របីជាមួយក្មេងៗ ព្រោះជាកិច្ចការស្រួលនិងស្រាលជាងគេ ។

ថ្ងៃមួយ នៅពេលហូបបាយក្រោមដើមពោធិជាមួយក្មេងពីរ-បីនាក់ អា**ហួត**កូនចឹក**ផាម-អ៊ួ** និយាយទៅកាន់អ្នក**ពេជ** :

- ថៅកែពូឯងចិត្តល្អណាស់ ព្រោះខ្ចប់បាយឱ្យពូឯង ជួនកាលមានក្ដាមប្រៃ ជួនកាលមានប្រហុកអាំង ។ ថៅកែខ្ញុំចិត្តមិនល្អទេខ្ចប់តែបបរគោកនិងអំបិលឱ្យខ្ញុំរាល់ព្រឹក ។ បើសិនណាជាគាត់អាចខ្ចប់បបរទឹកឱ្យខ្ញុំបាន ខ្ញុំពិតជាហុតបបររាវរហូតហើយ ។

គួរកត់សំគាល់ថាប្រជាជនចាស់ស្រឡាញ់គោក្របីរបស់ខ្លួន

ដូចកូនបង្កើត បើគោក្របីស្លាប់គេយំសោកដូចម៉ែឪគេស្លាប់ បើអ្នកថ្មីស្លាប់វិញគេនាំគ្នាសើចសប្បាយ ។ នេះហើយជាសោកនាដ្យកម្មនៃសង្គមខ្មែរយើង ដែលពួកទមិឡខ្មែរក្រហមវាធ្វើយ៉ាងណាដើម្បីឱ្យស្រុកឆាប់បានទៅជាកណ្ដាប់ដៃនៃប្រទេសជិតខាងយើង ។

មិត្ត**ទុន** មានជម្ងឺប្រចាំកាយ គឺជម្ងឺចុកពោះដែលអ្នកស្រុកស្រែចំការយើងហៅថាក្លូន ។ ជម្ងឺក្លូន គឺជាជម្ងឺក្រពះនោះឯង ។ ថ្ងៃមួយមិត្ត**ទុន** ក៏ធ្វើមរណកាលចោលនារី**តុម**ទៅ តែនារីបដិវត្តន៍ហាក់ដូចជាគ្មានទុក្ខសោកអ្វីបន្តិចសោះក្រោយពីប្ដីស្លាប់ ខុសប្លែកពីស្រីតណ្ហាដែលយំសោកបោកខ្លួន ឬជួនកាលលោតចូលក្នុងភ្នក់ភ្លើងសុខចិត្តស្លាប់ជាមួយប្ដី ។

មួយអាទិត្យក្រោយពីប្ដីស្លាប់ អ្នកមេម៉ាយ**តុម**ហៅឱ្យអ្នក**ពេជ**និងម្ដាយទៅសំណាក់នៅលើផ្ទះ ។ អ្នក**ពេជ**ខំយកចិត្តអ្នកមេម៉ាយថ្មីថ្មោងនេះណាស់ ។ រាល់ថ្ងៃមុនចេញទៅភ្ជួររាស់ អ្នក**ពេជ**រែកទឹកពីអណ្ដូងមកចាក់ពេញពាងទុកឱ្យអ្នកមេម៉ាយបដិវត្តន៍ ។ នៅពេលទំនេរអ្នកកម្លោះយើងទៅកាប់ឫស្សីមកធ្វើរបងផ្ទះ ជួសជុលផ្ទះជម្រះស្មៅនៅចំការមិត្តនារីយើង ។ អ្នកមេម៉ាយពេញចិត្តស្កុកនឹងអ្នក**ពេជ** ។



នារី**តុម** ដែលពីដើមធ្លាប់ស៊ីស្លាធ្មេញខ្មៅប៉ែនោះ ឥឡូវស្រាប់តែឈប់ស៊ីស្លាហើយខំដុសធ្មេញយ៉ាងសស្គុះ ។ នៅពេលយប់ជួនកាលអ្នកមេម៉ាយក្រហមស្លៀកសារុង *"ជ៉ាតិ"* ឬសារុងសូត្រហើយពាក់អាវម៉ុងតាហ្គុយ (montagut) ទៀត ។ របស់ទាំងនេះអ្នកមេម៉ាយបានមកពីអ្នកថ្មីដែលមកដូរចេក ខ្នុរ ល្ហុង ។ល។

អ្នកមេម៉ាយបដិវត្តន៍ក្រហម តាំងពីប្ដីស្លាប់ទៅ ដូចជាដូរអាកប្បកិរិយាច្រើនណាស់ អន់កាចហើយមិនសូវទិតៀនអ្នកថ្មីដូចកាលពីឆ្នាំមុននោះទេ ។ ពេលខ្លះ គេឃើញអ្នកមេម៉ាយក្រហមប៉ះខោអាវឱ្យអ្នក**ពេជ** ដែលជាហេតុធ្វើឱ្យអ្នកចាស់-អ្នកថ្មីមានការសង្ស័យច្រើន តែគ្មានអ្នកណាហ៊ានទិតៀនអ្វីទេ ព្រោះនារី**តុម**ជាប្អូនរបស់មេភូមិដែលមានអំណាចធំជាងព្រះចៅអធិរាជក្រុងចិនទៅទៀត ។

បីខែក្រោយមក នៅពេលអ្នកមេម៉ាយមិននៅផ្ទះ ម្ដាយអ្នក**ពេជ**និយាយទៅកូន :

- ម៉ែចង់ឱ្យកូនឯងមានគូស្រករហើយ ។
- ទេម៉ែ កូនមិនទាន់ចង់បានប្រពន្ធទេ ។
- កូនឯងហ៊ានរឹងទទឹងនឹងម៉ែផងឬ? ស្រុកយើងឥឡូវវាភ័ន្តប្រែ យើងត្រូវរកផ្លូវរស់ណាកូន! ។

- ចុះម៉ែចង់ឱ្យកូនរៀបការនឹងនារីណាមួយ?

- ជាមួយនឹងនារី**តុម**ណាកូន! ។

ឮតែនារី**តុម** អ្នក**ពេជ**ចង់ខ្យល់ចាប់ ព្រោះអ្នក**ពេជ**ដែលយកចិត្តអ្នកមេម៉ាយក្រហមក៏ដើម្បីរស់តែប៉ុណ្ណោះ ។ ក្នុងចិត្តវិញអ្នក**ពេជ**ឥតមានចិត្តសូម្បីតែបន្តិចក៏គ្មានដែរ ។ ម្យ៉ាងទៀតខ្លួនឯងជាកម្លោះព្រហ្មចារី មិនសមទៅយកមេម៉ាយដែលមានអាយុលើសខ្លួនយ៉ាងតិចក៏៥ឆ្នាំដែរនោះទេ ។

- មិនកើតទេអ្នកម្ដាយ កុំធ្វើបាបកូនអី! ។

- អ្នក**ពេជ**អើយ! អ្នក**ពេជ** កូនឯងធ្វើបុណ្យឱ្យម៉ែម្ដងទៅចុះ! តាមម៉ែទៅកូន ព្រោះកាលពីប៉ុន្មានថ្ងៃមុខនេះប្រធានភូមិមកនិយាយថា គាត់នឹងរៀបការប្អូនស្រីគាត់ទៅកូនឯង ។ បើកូនឯងមិនព្រមយើងមុខជាស្លាប់ទាំងអស់គ្នាហើយ! ។

ទាល់តម្រិះ អ្នក**ពេជ**ក៏ព្រមតាមម្ដាយទៅហោង ។

ថ្ងៃរៀបការកាន់តែខិតមកដល់ហើយ ។ ព្រឹកមួយនោះអ្នកមេម៉ាយក្រហមនិយាយទៅកាន់អ្នក**ពេជ** :

- បង**ពេជ**អា៎! ថ្ងៃនេះមិនបាច់ទៅភ្ជួរទេ ព្រោះអូនដូចជាមិនស្រួលខ្លួន ប្រហែលខ្យល់ចាប់ហើយ... ។



អ្នក**ពេជ**ឮនារី**តុម**ហៅថាបង ភ័យចង់លោះព្រលឹង មុខឡើងក្រហមព្រឿងៗ....

- បងឯង (អ្នកមេម៉ាយបន្ត) មកកោសកញ្ចឹងកឱ្យអូនបន្តិចមក!... ។

- ទេមិនកើតទេនារី**តុម** ព្រោះខ្ញុំខ្លាចខុសសីលធម៌ទី៣ (សីលធម៌ទី៣ គឺរឿងស្នេហានៅជំនាន់**អាពត** ប្រុសស្រីណាហ៊ានស្រឡាញ់គ្នាអង្គការយកទៅសម្លាប់ចោល) ។

- បងឯងឈប់ហៅខ្ញុំថានារី**តុម**ទៀតទៅ ព្រោះយើងជិតរៀបការហើយ ។ ម្យ៉ាងទៀតរឿងសីលធម៌ស្អីគេនោះ បងឯងកុំនឹកនាដល់វាទៀត ព្រោះអូនឈប់ធ្វើបដិវត្តន៍ហើយ ។ មក មកជិតអូនមក!... ។

ថ្ងៃនោះម្ដាយអ្នក**ពេជ**ឥតនៅផ្ទះទេ ព្រោះគាត់ទៅឱ្យបាយជ្រូក ។ អ្នក**ពេជ**ដើរបៀបភ័យៗទៅក្បែរអ្នកមេម៉ាយ ។ អ្នក**ពេជ**យកលុយទៅកោសកញ្ចឹងកអ្នកមេម៉ាយ ដៃឡើងញ័រតគាត់ ។ កោសយ៉ាងណាក៏មិនឃើញក្រហម ។

- ឥតក្រហមទេ នា..រី..តុ..ម..អើយ (អ្នក**ពេជ**និយាយមិនចង់ចេញ) ។

- បើអញ្ចឹងបងឯងកោសខាងមុខម្ដង! ។

– មិនកើតទេ! មិនកើតទេ! (អ្នក**ពេជ**ឆ្លើយ) ។

អ្នកមេម៉ាយទាញដៃអ្នក**ពេជ**មកប្រចាប់ ។

– បងឯងស្រឡាញ់អូនឬមិនស្រឡាញ់? អូនមិនដែលស្រឡាញ់ប្រុសណាម្ដងឡើយក្រៅពីបងឯង ។ ប្ដីអូនពីមុន អូនមិនដែលឱ្យមកបៀតទេ ។ កម្មអាក្រក់ណាស់ ព្រោះព្រះមិនឱ្យមកជួបបងឯង កាលអូននៅអាយុដប់ប្រាំពីរ ។

លុះស្នេហាចូលលុក អ្នកមេម៉ាយក្រហមភ្លេចឯ**ម៉ាក-ឡេនីន** (Marx-Lénine) ទៅជានឹកឃើញព្រះឯណាឆ្កុយទៅវិញទៅ ។ គួរឱ្យអស់សំណើច!!...

ថ្ងៃរៀបការមកដល់...

ប្រធានភូមិ អនុញ្ញាតឱ្យអ្នកថ្មីបានឈប់សម្រាកបាន ២ថ្ងៃ ។ អ្នកភូមិពេញសប្បាយចិត្តណាស់ដឹងគុណអ្នក**ពេជ**គ្រប់ៗគ្នា ព្រោះតាំងមករស់នៅក្នុងភូមិ**ជ័យសម្បត្តិ**ជាងមួយឆ្នាំហើយ មិនមានថ្ងៃណាមួយបានសម្រាកទេ គឺធ្វើការទាំងយប់ទាំងថ្ងៃ ។ អ្នកដែលសប្បាយជាងគេគឺ **អាហួត**កូនចិក**ផាម-អូ** ព្រោះវាយល់ថា *"ប៉ារទី"* (Parti) វាឡើងហើយនៅពេលនេះ ព្រោះអ្នក**ពេជ**ជិតដិតនិងវាខ្លាំងណាស់ ឃ្វាលក្របីនិងហូបបាយនៅវាលស្រែជាមួយគ្នារៀងរាល់ថ្ងៃ ។

នៅព្រឹកថ្ងៃការ **អាហួត**និយាយទៅកាន់អ្នក**ពេជ** :



– ពូ**ពេជ**អ្ហា... ពូឯងជួយនិយាយនឹងប្រពន្ធពូឯងផង ព្រោះខ្ញុំចង់ប្ដូរចៅកែ ។ ចៅកែខ្ញុំកាចណាស់ ខ្ញុំហូបបបរតែនឹងអំបិលទេ ។

គួរកត់សំគាល់ថា ប្រជាជនចាស់គេមានស្រូវជង្រុក មានចាន មានផ្ទាំង មានចំការចេក ចំការខ្នុរ ដែលជាកម្មសិទ្ធិរៀងខ្លួននៅឡើយ ។ អ្នកថ្មីណាហ៊ានលួចបេះខ្នុរ ឬល្ហុង ច្បាស់ជាបាត់ខ្លួន ។

រាត្រីច័ន្ទទឹកឃ្មុំ (Honeymoon) មកដល់ហើយ ។ ម្ដាយអ្នក**ពេជ**នាំកូនកម្លោះចូលបន្ទប់ ។

រាត្រីរនោចនៅក្នុងរដូវវស្សា ។ ខ្យល់បក់មកយ៉ាងខ្លាំង ។ ផ្លេកបន្ទោរចាំងផ្លេកៗ ។ ផ្គរនិងរន្ទះលាយឡំគ្នាបញ្ចេញសម្លេងខ្ទ័រខ្ទា មើលតែសម្លេងគ្រាប់បែក B52 អាមេរិកកាំងទម្លាក់លើក្បាលយួនឯទីក្រុងហាណូយ ។ មែកឈើពុកបាក់ធ្លាក់មកដីឮសូរព្រាវៗ ។ ភ្លៀងដូចគេចាក់ទឹក ។ អ្នកថ្មីដែលរស់នៅក្នុងតូបឫស្សីរត់មកជ្រកក្រោមផ្ទះអ្នកចាស់ ព្រោះខ្យល់បក់ខ្លាំងពេក នាំយកជញ្ជាំងឫស្សីនិងដំបូលខ្ទមទៅបោះចោលនៅក្នុងវាលស្រែដែលនៅមិនឆ្ងាយប៉ុន្មានពីភូមិឡើយ ។

យប់នោះ អ្នក**ពេជ**បែកញើសជោកខ្លួនថ្វីបើធាតុអាកាសត្រជាក់ស្ទើរដល់ឆ្អឹងខ្នង ។ ខោអាវជោកទៅដោយញើសមិនខុសពីយើងភ្លួរស្រែនៅក្រោមទឹកភ្លៀងឡើយ ។ ជើងថ្មីជួបនិងជើងចាស់ធ្វើឱ្យកំលោះព្រហ្មចារីយើងភ័យស្ទើរលោះព្រលឹង ។

ផ្ទះអ្នកមេម៉ាយ**តុម**ធំទូលាយណាស់ តែមានបន្ទប់ដេកតែមួយគត់នៅក្បែរចង្ក្រានបាយ ។ បន្ទប់នោះរាងបួនជ្រុងស្មើ ជញ្ជាំងធ្វើអំពីឫស្សីបិទបាំងទៅដោយស្លឹកខេមា ។ នៅក្នុងបន្ទប់ក្រាលដោយកន្ទេលកន្សែងមួយយ៉ាងធំ គេឃើញតែខ្នើយពីរនិងកូនឈើងមួយតូចនៅលើក្បាលដំណេក ។ នៅលើឈើងគឺចង្កៀងប្រេងកាតមួយយ៉ាងកញ្ចាស់ ។

ម្ដាយអ្នក**ពេជ** សម្រាន្តនៅមាត់ទ្វារផ្ទះ ។ ចង្កៀងប្រេងកាតបំភ្លឺព្រឹមៗក្នុងបន្ទប់ ។ ភ្លៀងផ្គរចេះតែបន្តទៅទៀត អ្នកមេម៉ាយខិតទៅជិតប្ដីថ្មី ។

- យី! (មេម៉ាយក្រហម) ម៉េចក៏អាវបងទទឹកជោកអញ្ចឹង? និយាយសឹងមិនទាន់ចង់ផង មេម៉ាយបដិវត្តន៍ស្ទុះទៅដោះអាវឱ្យប្ដី ។ ពេលនោះអ្នក**ពេជ**ដូចជាមនុស្សឥតវិញ្ញាណ ព្រោះតាំងតែចេញពីពោះម៉ែមក អ្នកមិនដែលប៉ះពាល់ស្រីភេទទាល់តែសោះ ។



- បងឯងអៀនខ្មាសអីយើងជាប្ដីប្រពន្ធនឹងគ្នាទេតើ!

អ្នក**ពេជ**ឥតតប ភ័យខ្លួនឡើងញ័រចំប្រប់ ។ បន្តិចក្រោយមកស្រាប់តែវាររតើម១ ទៅដេកក្បែរម្ដាយវិញ ។ ម្ដាយដេញកូនឱ្យចូលបន្ទប់ ។ អ្នក**ពេជ**ដើរលប១ចូលបន្ទប់ដេកក្រៀន១រហូតទល់ភ្លឺ ។

អ្នកមេម៉ាយនឹកខកចិត្តជាខ្លាំង ព្រោះនឹកថាបានឡើងទៅគៀងទានៅរាត្រីទឹកឃ្មុំនេះហើយ ។

រាត្រីទីពាមកដល់ ។ នៅក្រោមផ្ទះ គឺង្គក់ ហ៊ីង ក្អាត់យំព្លាន់ដូចគេប្រគុំដូរ្យតន្ត្រីនៅវេលាយប់ ។ ភ្លៀងធ្លាក់តិច១នៅឡើយ ។

- មកក្បែរអូនមកបង**ពេជ!** ។

អ្នក**ពេជ**ខិតទៅក្បែរប្រពន្ធ ។ យប់នោះ អ្នកមេម៉ាយក្រហមស្លៀកសារុងសូត្រចងពុងឃើញសុដនពាក់កណ្ដាល ។ អ្នក**ពេជ**លបមើលប្រពន្ធ ស្រាប់តែភ្ញាក់ដូចគេចោល នឹកក្នុងចិត្ត *យីនារី**តុម**ស្អាតទេតើ!! នាងពិតជាបុប្ផាលាក់ខ្លួននៅក្នុងព្រៃមែន ។ ទ្រូង កញ្ចឹងកសក្បុស សាច់ហ្មត់ខៃនៅក្រោមពន្លឺចង្កៀងប្រេងកាត ។ នាងមិនសមបានប្ដីមុខខ្មៅក្រញោះ១ដូច្នេះសោះ! ។*

ពេលអ្នក**ពេជ**កំពុងរវើរវាយ អ្នកមេម៉ាយបដិវត្តន៍ទាញដៃប្ដីថ្មមៗមកដាក់លើទ្រូង ហើយនិយាយតិចៗទៅកាន់អ្នក**ពេជ** ។

- បងអើយ! អូននៅភាពព្រហ្មចារីនៅឡើយទេ ព្រោះប្ដីមុនអូនអត់ឱ្យគាត់មកជិតទេ ។ បើមិនជឿបងសាកលមើលទៅ ។

រាត្រីទី៣ ពិតជាអនុស្សាវរីយ៍ដែលអ្នក**ពេជ**មិនអាចបំភ្លេចបានឡើយ ។ ព្រោះគេទាំងពីរនាក់ពិតជាបានឡើងទៅគៀងទានៅឯស្ថានលើទាំងអស់គ្នាមែន ។

និយាយពី**អាហ្វួត**កូនចឹក**ផាម-អ្វ៊** រង់ចាំជួបអ្នក**ពេជ**ស្ទើរផ្សាភ្លែកនៅឯវាលស្រែដោយវាចង់ប្ដូរថៅកែក្របី ។ ថ្ងៃទី៤ ទើបលេចអ្នក**ពេជ**ទៅឃ្វាលក្របី ។ **អាហ្វួត**អរខ្លាំងណាស់ស្ទុះទៅចាប់ដៃអ្នក**ពេជ** ។

- ម៉េចទៅពូ**ពេជ** ពីរ-បីយប់មុខនេះ?

អ្នក**ពេជ**មុខឡើងក្រហមដោយអៀននឹង**អាហ្វួត** ។ ពេលបាយមកដល់ **អាហ្វួត**ស្ទុះទៅលាកញ្ចប់បាយអ្នក**ពេជ** ស្រាប់តែវាស្រែកយ៉ាងរំភើបចិត្ត :

- យីពូ**ពេជ** ឆ្ងាញ់ងាប់ហើយលើកនេះ ។ ភ្លៅមាន់អាំងប្រហុកចិញ្ច្រាំនឹងគល់ស្លឹកគ្រៃ ព្រមទាំងម្ទេសនិងត្រប់ស្ងួយ ។ ពូឯងសំណាងធំហើយព្រោះមានប្រពន្ធអ្នកមាន ។



ដោយសារអ្នក**ពេជ** **អាហ្វួត**បានបាយស៊ីសឹងរាល់ថ្ងៃ ។

បីអាទិត្យក្រោយមកនៅយប់ខែភ្លឺ អ្នក**ពេជ**អុចធូបបីសរសៃយកទៅដោតនៅលើជញ្ជាំងក្បាលដំណេក ហើយនិយាយសឹងមិនឮថា :

- មិត្ត**ទុន**អើយមិត្ត**ទុន** ខ្ញុំសុំខមាទោសព្រោះខ្ញុំជ្រុលការជាមួយប្រពន្ធមិត្ត ។ មិត្តមុខជាឃើញខ្ញុំហើយនៅរាត្រីទី៣នោះ បើឃើញមែនសូមមិត្តកុំប្រកែប្រកាន់ ។ សូមវិញ្ញាណក្ខន្ធមិត្តកុំនៅវិលវល់ក្នុងភូមិ**ជ័យសម្បត្តិ** ។

អ្នក**ពេជ**ចង់បន្តទៅទៀត តែអ្នកមេម៉ាយក្រហមនៅក្បែរនោះទាញដៃប្ដី ចូលក្នុងមុងនិន្ទ្រាលង់លក់ទៅហោង ។

ចុងឆ្នាំ ១៩៧៨ យួនវាយលុកចូលស្រុកខ្មែរ ។ ខ្មែរក្រហមបាតជើងសព្រាតរត់ចូលព្រៃហើយលេចឮដំណឹងថា របបថ្មីជារបបសេរី ។ នៅពេលស្ថានការណ៍កំពុងច្របូកច្របល់ពេញបន្ទុកនោះអ្នក**ពេជ**ក៏នាំម្ដាយរត់ចេញពីភូមិ**ជ័យសម្បត្តិ** ទុកឱ្យអ្នកមេម៉ាយក្រហមយំសោកសង្រេង ព្រោះប្ដីរត់ចោល ។ ក្រោយមកម្ដាយអ្នក**ពេជ**ក៏ធ្វើមរណកាលចោលកូនទៅ ។ អស់សង្ឃឹមអ្នក**ពេជ**ក៏ធ្វើដំណើរទៅទិសខាងលិច ហើយរស់នៅក្នុងជំរំ**ខៅអ៊ីដាង** (ស្រុកសៀម) បានមួយឆ្នាំគត់ទើបមកដល់ស្រុកបារាំង ។

# មេម៉ាយសុីវីល័យ

ថ្ងៃទី ២០ ធ្នូ ១៩៨០ អ្នក**ពេជ**បានមកដល់ចំណតអាកាសយាន *"ស្ហាលដឺហ្គោល"* (Aéroport Charles de Gaule) ជាមួយនឹងជនភៀសខ្លួនមួយចំនួនដែលភាគច្រើន ច្រើនតែក្មេងនិងស្រីមេម៉ាយ ដែលពួក**អាពត**យកប្ដីទៅសម្លាប់ចោលក្នុងចន្លោះឆ្នាំ ១៩៧៥-៧៨ ។

ចំពោះអ្នក**ពេជ** នេះជាលើកទី១ហើយដែលបានមកជាន់ដីស្រុកបារាំង ។ អ្នក**ពេជ** ព្រមទាំងខ្មែរឯទៀតឡីនឡង់ដូចឈ្លូសចូលស្រុក ។ ក្រឡេកមើលទៅត្រង់ណាល្អនិងប្លែករហូត ។ បើស្រីបារាំងវិញ ល្អទាំងអស់ឥតឃើញមានអាក្រក់សោះ ។ ក្រឡេកមកខ្លួនឯងដូចស្វា ។ អាវ *"ស្ហឺមីស្ហ"* (Chemise) ពាក់ជិតមួយខែមកហើយមិនទាន់បោកនៅឡើយ ស្បែកជើងជិបតុងមួយគូពាក់តាំងពីជំរំ**ខៅអីដាង**រហូតមកដល់ស្រុកបារាំង ។



នៅពេលអ្នក**ពេជ**កំពុងរវើរវាយ ស្រាប់តែឮបារាំងហៅឱ្យឡើងឡាន *"ការ"* (Car) មួយយ៉ាងធំ ។ ជនភៀសខ្លួនខ្មែរប្រហែល ៥០នាក់ នាំគ្នាចេញមកក្រៅ ។ នៅពេលដែលទ្វារស្វ័យប្រវត្តិរបើកភ្លាមខ្យល់ត្រជាក់បក់វូរ អ្នក**ពេជ**ភ្លាត់មាត់ :

- យីយើងនាំគ្នាដើរចូលទឹកកកអីទេតើ!

នៅពេលជនភៀសខ្លួនខ្មែរឡើងឡានរួចអស់ហើយ រថយន្តដ៏ធំនេះក៏បើកតិចៗចេញពីអាកាសយាន ។ ម្នាក់ៗនឹកសួរខ្លួនឯងថា តើបារាំងនាំអញទៅឯណាអេះ? អ្នក**ពេជ**នឹកក្នុងចិត្ត : *ចង់ឯងនាំអញទៅណាទៅក៏ទៅ ព្រោះអញរួចពីអាបិសាចខ្មែរក្រហមហើយ!* ។

រថយន្តបើកកាត់ទីក្រុង រួចហើយវាលចំការដ៏ធំធេង ។ ជនភៀសខ្លួនជជែកគ្នាអែ ។ ទីវាលដ៏ធំធេងនោះមានពណ៌សក្បុស ព្រោះទឹកកក (neige) ធ្លាក់នៅពេលមួយថ្ងៃមុនមិនទាន់រលាយអស់នៅឡើយ ។ ដើមឈើឥតមានស្លឹក ឃើញតែមែកក្ដុយៗ ។ ជនភៀសខ្លួនយល់ថាឈើនៅស្រុកបារាំងសុទ្ធតែឈើងាប់ ។ ដូចនេះគេមិនបាច់ពិបាកនឹងឱសដុតទេ ។

៥ម៉ោងក្រោយមក រថយន្តបានមកដល់ទីក្រុងកង (Caen) រួចហើយបើកកាត់ក្រុងនេះ រហូតដល់ភូមិមួយឈ្មោះ **ប្រេវីល**

(Bréville) ដែលសង់នៅកណ្ដាលវាលស្រែ ។ រថយន្តបើកចូលទៅក្នុងមជ្ឈមណ្ឌលសម្រាប់ទទួលអ្នកវ៉ាកង ។ នៅក្នុងមជ្ឈមណ្ឌលគេឃើញអាគារមួយដ៏ធំចម្លែក ។ ការិយាល័យ បុគ្គលិក កន្លែងលក់ស្រា កន្លែងទទួលទានបាយ គឺនៅក្នុងអាគារនោះតែម្ដង ។ ក្រៅពីភូមិគ្រឹះនេះ គេឃើញមានផ្ទះតូចៗជាច្រើន ដែលសង់នៅក្បែរៗគ្នាសម្រាប់ទទួលអ្នកវ៉ាកងឱ្យស្នាក់នៅ ។ បារាំងបានយកផ្ទះតូចៗនេះដាក់ជនភៀសខ្លួនខ្មែរ ។ បើតាមកម្មវិធីដែលគេគ្រោងទុក ខ្មែរយើងត្រូវរស់នៅទីនេះពី៦ខែទៅមួយឆ្នាំ ដើម្បីរៀនភាសាបារាំងនិងរបៀបរស់នៅស្រុកគេ ។

ក្នុងចំណោមខ្មែរភៀសខ្លួន គេឃើញមានមនុស្សច្រើនបែបនិងច្រើនធី ។ មនុស្សខ្វាត់ព្រាត់មកម្នាក់ឯង គឺអ្នក**ពេជ** ។ អ្នកមានប្ដីប្រពន្ធកូនជួបជុំគ្នាមានតែមួយគ្រួសារគត់ គឺគ្រួសារខ្ញុំ ។ បើនិយាយពីមេម៉ាយមានពីរធុន មេម៉ាយចំណាស់អាយុពី ៥០ ទៅ ៦០ មាន៣គ្រួសារ មេម៉ាយក្មេងៗពី ២៥ឆ្នាំ ទៅ ៣០ឆ្នាំ មាន៤គ្រួសារ ក្រៅពីនោះមានក្មេងជំទង់ ស្មាវ កម្លោះប្រហែល ១០នាក់ទៀត ។

មកដល់សម្រាកបានពីរអាទិត្យ បារាំងបញ្ជូនគ្រូបារាំង៣នាក់មកបង្រៀនពួកយើង ។ គ្រូស្រី ២នាក់ (ក្រមុំម្នាក់ Mlle



Francoise និងអ្នកស្រី **ដឺគ្រេម៉ុង** Degrémont) និងគ្រូប្រុសម្នាក់ទៀតឈ្មោះ **វ៉ាំងសង់** (Vincent) ។ អ្នកដែលចេះបារាំងគួរសមមានខ្ញុំនិងអ្នក**ពេជ** តែបារាំងអ្នក**ពេជ**ជាបារាំងជំនាន់ខេមរយានកម្ម (Khmérisation) ម្ល៉ោះហើយអ្នក**ពេជ**ស្ដាប់បារាំងមិនសូវបានទេ តែចំណាំពាក្យមួយម៉ាត់ជាងគេគឺពាក្យ *ប៉ាដុង* (Pardon) ដែលគ្រូបង្រៀននៅស្រុកខ្មែរ ។

អ្នក**ពេជ** ជាមនុស្សចេះគួរសមណាស់ បើដើរក្បែរបារាំងគឺប៉ាដុងរហូត ជួនកាលដើរប៉ះកញ្ចក់ក៏ភ្លាត់មាត់ប៉ាដុងដែរ ដែលជាហេតុធ្វើឱ្យបារាំង-ខ្មែរសើចគិល ។

អស់រយៈពេលពីរខែហើយ ដែលយើងមករស់នៅក្នុងមជ្ឈ-មណ្ឌលទទួលអ្នកវ៉ាកង ។ គេសង្កេតឃើញមានការជឿនលឿននិងការផ្លាស់ប្ដូរជាច្រើននៅក្នុងរង្វង់ជនភៀសខ្លួនខ្មែរ គឺគេជឿនលឿនខាងភាសា និងខាងមិនសូវខ្លាចបារាំង ។ ម្យ៉ាងទៀតកាលមកដល់លើកដំបូង ជនភៀសខ្លួនខ្មែរមានរូបរាងដូចស្វា បើប្រៀបធៀបទៅបារាំង ។ ឥឡូវនេះ ដោយសារត្រូវជាតិទឹកដោះគោ ប័រ (Beurre) ហ្វ្រូម៉ាស្ត ស្រាក្រហម ។ល។ ហើយស៊ាំនឹងធាតុអាកាសផង ម្នាក់ៗមានរូបរាងស្អាតជាងមុខឆ្ងាយណាស់ ជាពិសេសមេម៉ាយក្មេងៗ ស្រាប់តែឡើងក្រភើៗ សាច់ទ្រលុកទ្រលន់

សឹងគ្រប់ៗគ្នា ។

Mademoiselle Françoise បង្រៀនភាសាបារាំងដល់ក្រុមអ្នក**ពេជ** ។ អ្នកគ្រូនេះមានរូបរាងស្អាតណាស់ អាយុប្រហែល ២២ ឬ ២៣ឆ្នាំប៉ុណ្ណោះ ។ គាត់ចូលចិត្តស្លៀកខោអាវខើចៗ ជួនកាលចេញភ្លៅ ជួនកាលចេញគល់សុដន ។ តែស្រីបារាំងជាការធម្មតារបស់គេទៅហើយ គេមិនចេះខ្មាសដូចស្រីខ្មែរយើងទេ ។ ម៉េម៉ាយចាស់ៗនៅពេលជួបកញ្ញា Françoise ម្តងៗ ព្រើអស់ហើយខ្លួនព្រោះខ្មាសគេជួសគាត់ ។ អ្នកគ្រូនេះចូលចិត្តអ្នក**ពេជ**ណាស់ ជួនកាលគាត់មកអង្គុយកៀកនឹងអ្នកពោះម៉ាយយើង ធ្វើឱ្យអ្នក**ពេជ**អៀនមុខក្រហមព្រឿងៗ ។

អ្នក**ពេជ** ជាបុរសមួយមានរូបសង្ហាណាស់ ខ្ពស់ស្រឡះ សម្បុរសណ្តែកបាយ ដែលជាពណ៌បារាំងចូលចិត្ត ជាពិសេសបារាំងស្រីៗតែម្តង ។ អ្នក**ពេជ**ចេះគួរសមណាស់នឹងអ្នកគ្រូ មិនខុសពីសិស្សខ្មែរគោរពគ្រូនៅស្រុកខ្មែរយើងឡើយ ។

ថ្ងៃមួយ Françoise ហៅអ្នក**ពេជ**ទៅលេងផ្ទះ អ្នក**ពេជ**អេះអុញៗរបៀបខ្មាស តែទីបំផុតក៏សុខចិត្តទៅ ។ ហៅមួយដងរាងខ្មាស ពីរដងអន់ខ្មាស បីដងអ្នក**ពេជ**លេងខ្មាសតែម្តង ។ ក្រោយមកគេឃើញអ្នក**ពេជ**ទៅផ្ទះ Mademoiselle Françoise



សឹងរៀងរាល់ថ្ងៃ ។ មុនដំបូងអ្នកគ្រូបង្ហាត់សិស្សឱ្យចេះរាំ គឺរាំវិធីប្រដាល់នៅលើគ្រែ ។ អ្នក**ពេជ**ចេះក្បាច់គុនច្រើន ដោយសារ Mademoiselle Françoise តែហាត់ក្បួនគុននេះធ្វើឱ្យអ្នក**ពេជ**ស្រកគីឡូច្រើនណាស់ ។ ក្រោយមកអ្នកគ្រូ Françoise ឈប់បង្រៀនបារាំងដល់ជនភៀសខ្លួនខ្មែរ ។ ចំណែកអ្នក**ពេជ**ក៏ឈប់ទៅផ្ទះគាត់ដែរ ។ ថ្ងៃមួយខ្ញុំសួរទៅអ្នក**ពេជ** :

- អ្នក**ពេជ**ឯងម៉េចក៏ឈប់ទៅផ្ទះ Mademoiselle Françoise ?

- ខ្ញុំឈប់ទៅហើយបងអើយ ពីព្រោះកម្លាំងធាតុគាត់ខ្លាំងជាងខ្ញុំឆ្ងាយណាស់ ។ ពេលខ្លះខ្ញុំទំទប់ទាល់តែធ្លាក់ពីលើគ្រែ ។ មិនបានទេបងអើយជាងជ្រូកពុល ឬដីរីចុះប្រេងទៅទៀត ។

តាំងពីសេពគប់ Mademoiselle Françoise មកអ្នក**ពេជ**លេងចេះអៀនខ្មាសស្រី ឬក៏របៀបស្ទុយដូចលើកមុនទៀតហើយ ។ បារាំងដែលធ្វើបាយឱ្យជនភៀសខ្លួនខ្មែរហូបមាន ២នាក់ ប្រុសម្នាក់ស្រីម្នាក់ ។

ស្រីគឺកញ្ញា ប៉ាទ្រីស្យា ( Mademoiselle Patricia) ។ Mademoiselle Patricia មិនស្រស់ដូច Mademoiselle Françoise ទេតែនាងមានសាច់ជាងអ្នកគ្រូ Françoise ។ អ្នក

**ពេជ** ក្រោយពីលែងទាក់ទងជាមួយ Mademoiselle Françoise មក ក៏ជាប់ដៃជាមួយ Mademoiselle Patricia ទៅ ។

យើងស្លេះអ្នក**ពេជ**ទុកមួយកន្លែងសិន ហើយត្រឡប់មករកមេម៉ាយខ្មែរៗម្តងដែលកំពុងតែជ្រួលជ្រើមសម្បើមណាស់ ព្រោះណាមួយវាអត់កម្លោះពោះម៉ាយ ណាមួយទៀតដល់បរិភោគប័រហ្វ្រូមាស្ល ទឹកដោះគោឆៅ វាមានកម្លាំងខ្លាំងក្លា ហើយចេះតែនឹកឃើញរឿងផ្តេសផ្តាស ព្រោះវាអត់យូរណាស់មកហើយ ។

ក្នុងចំណោមមេម៉ាយទាំង ៨នាក់ គេសង្កេតឃើញមេម៉ាយម្នាក់បែបរសាប់រសល់ជាងគេ ។ អ្នកមេម៉ាយនេះឈ្មោះ **ស៊ីវ-ហ៊ាង** អាយុប្រហែល ២៩ឆ្នាំ ហើយមានកូនតូចៗ ២នាក់ ។

**ស៊ីវ-ហ៊ាង** មានរូបសម្បត្តិឆើតឆាយល្អដាច់ពីមេម៉ាយឯទៀតៗ ។ នាងចូលចិត្តតែងខ្លួនណាស់ មិនសូវគិតពីរឿងកូនចៅប៉ុន្មានទេ ។ ខ្មែរឱ្យឈ្មោះអ្នកមេម៉ាយ**ស៊ីវ-ហ៊ាង**ថា *"មេម៉ាយស៊ីវិល័យ"* ។ អ្នកដែលមិនស្គាល់នាងពិតជាយល់ថានាងជាស្រីក្រមុំ ។ បន្ទាប់នាង**ស៊ីវ-ហ៊ាង**នៅជាប់នឹងអ្នកមេម៉ាយមួយទៀតដែលជនភៀសខ្លួនខ្មែរឱ្យឈ្មោះថា *"យាយស៊ីហ្គារ"* (Cigare) ព្រោះគាត់ចូលចិត្តជក់ស៊ីហ្គារ ។ យាយស៊ីហ្គារចំណាស់បន្តិចទៅហើយ ហើយមិនសូវរសាប់រសល់ដូចមេម៉ាយឯទៀតៗទេ ។



ចំណែកកំលោះៗមាន ៤នាក់ ។ អ្នកទាំង ៤នាក់នេះក្លាយជាគោទ្បើងកអស់ទៅហើយ ។ អាបី-បួននាក់នេះមិនហ៊ានញ៉ែកូនបារាំងទេ ព្រោះវាមិនសូវចេះភាសាបារាំង ហើយរបៀបស្ទុយៗខ្លាចស្រីបារាំងទៅទៀត ។

យើងចូលមកដល់រដូវក្តៅ (été = summer) ។ ជំរំ**ប្រេវីល** (Bréville) ដែលពុំសូវមានអ្នករវ៉ាកងទៅទីយៈរដូវ (Printemps = Spring) ឥឡូវបិទផ្លាក *"ពេញ"* (Complet = no vacancy) ។ បារាំងចាស់បាននៅលាយឡំជាមួយជនភៀសខ្លួនខ្មែរពេញមួយរដូវក្តៅ ។

យប់មួយនោះ វេលាម៉ោង ១១ ធាតុអាកាសរាងស្អុះស្អាប់ខុសធម្មតា ខ្ញុំចេញមកដើរលំហែរកាយក្នុងមជ្ឈដ្ឋានស្រាប់តែវូមវាក់នឹងយាយ**ស៊ីហ្គារ**អង្គុយបង្អុយផ្សែងបារីក្រោមដើម *"ប៉ោម"* (Prommier = Apple tree) រអ៊ូមើលតែឃ្មុំរកផ្កា ។

\- វាម៉េចទៅហើយ យាយ**ស៊ីហ្គារ**អើយ? (ខ្ញុំសួរទៅគាត់) ។

\- វាម៉េច នរណាដេកលក់លោកអើយ បើវារង្គើអស់ហើយខាងផ្ទះខ្ញុំឯណោះ! ។

\- វារញ្ជួយផែនដី ឬយ៉ាងម៉េចយាយ**ស៊ីហ្គារ**? ។

- អា**តុន** វាចូលទៅក្នុងបន្ទប់នាង**ស៊ីរីល័យ** (អា**តុន**ជាក្មេងកម្លោះម្នាក់មានមាឌក្រអាញ) អានោះខ្លាំងជាង**តូរូ** (Taureau = Bull) ទៅទៀត ។ ប៉ុន្មានយប់ហើយគ្មានបានដេកពួនអីទេខ្ញុំ ។ មួយយប់ៗជញ្ជាំងខ្ញុំរញ្ជួយយ៉ាងតិច ៣ដង ។

- ចុះយ៉ាងម៉េចក៏ជញ្ជាំងរញ្ជួយទៅវិញយាយ**ស៊ីហ្គារ**?

- មិនរញ្ជួយយ៉ាងម៉េច បើអាគ្រែវាទៅប៉ះនឹងជញ្ជាំងខ្ញុំសឹងបាក់ទៅហើយ ។ ទោះជាឯងខ្ញុំក្អកគ្រហែមយ៉ាងណា ក៏វាមិនញញើតញឹត... ញឹន ។

- ក្រែងយាយឯង អត់យូរជូរមាត់ទេដឹង! (ខ្ញុំបន្ថែម) ។

- កុំនិយាយផ្ដេសផ្ដាសអីចឹងលោក ។ ចំណាស់ខ្ញុំហើយខ្ញុំលែងនឹកនាឃើញវាទៀតហើយ ។

ពីរ-បីអាទិត្យក្រោយមក គេឃើញអ្នកមេម៉ាយស៊ីរិល័យបណ្ដើរបារាំងក្មេងម្នាក់ ។ យើងត្រឡប់មកអ្នក**ពេជ** និងកញ្ញា**ប៉ាទ្រីស្យា**ម្ដង ។ ពីរ-បីខែហើយ ដែលអ្នក**ពេជ**ដើរជាមួយកញ្ញា**ប៉ាទ្រីស្យា** តែអ្នក**ពេជ**ឥឡូវខុសគ្នាពីអ្នក**ពេជ**ជំនាន់មុនខ្លាំងណាស់ តាំងពីអាកប្បកិរិយា ពីរូបរាង ។ មុខឡើងស្លាំង គូទដូចគូទដូង ពេលខ្លះដើរចង់ពាន់ជើង ។ បើឃើញស្រីបារាំង អ្នក**ពេជ**គេចរហូតដូចជាបាក់ស្បាត ។ ថ្ងៃមួយខ្ញុំសួរទៅអ្នក**ពេជ** :



- ម៉េចទៅអ្នក**ពេជ** កញ្ញា**ប៉ាទ្រីស្យា**?

- ខ្ញុំលែងហ៊ានក្បែរវាទៀតហើយបងអើយ !

- ម៉េចក៏អញ្ចឹងទៅហើយ?

- មីនោះខ្លាំងជាង Mademoiselle Françoise ទៅទៀត ខ្ញុំទប់មិនឈ្នះទេ ។ ហ៊ានតែបន្តទៅទៀតច្បាស់ជាដេកពេទ្យហើយខ្ញុំ ។

ក្រោយពីរត់ចោល Mademoiselle Patricia មក អ្នក**ពេជ**តាមទៅញ៉ែអ្នកមេម៉ាយ**ស៊ីវ-ហ៊ាង**ម្ដង ។ ថ្ងៃមួយអ្នកមេម៉ាយស៊ីរិល័យនិយាយទៅកាន់អ្នក**ពេជ** :

- ហួសពេលហើយពូ**ពេជ**អើយ ។ ខ្ញុំលែងប្រថុយហើយជាមួយប្រុសខ្មែរ ព្រោះមិនស៊ីរិល័យ ហើយមិនចេះថ្នាក់ថ្នមស្រីដូចបារាំងទេ ។

យាយ**ស៊ីហ្គារ**នៅក្បែរនោះបន្ថែម :

- ត្រូវហើយអា**ហ៊ាង**អើយ! ព្រោះប្រុសខ្មែរវាមិនចេះស្ទាបតុម្ពកំបោរ វាមិនចេះលិទ្ធកែងជើងដូចបារាំង ។ល។ និង ។ល។

ក្រោយពីផ្សងព្រេងអស់ចិត្តជាមួយស្រីបារាំងមក អ្នក**ពេជ**ហាក់ដូចជាមានវិប្បដិសារី នឹកដល់មេម៉ាយក្រហមនៅភូមិ**ជ័យសម្បត្តិ** ។